Cambodia Development Resource Institute

# យុទ្ធសាស្ត្រកំណើនថ្មីរបស់ប្រទេសកម្ពុជា៖
## ការវាយតម្លៃកំណើនរយៈពេលមធ្យម និងវែង
## សម្រាប់ការអភិវឌ្ឍប្រកបដោយភាពធន់ បរិយាបន្ន និងចីរភាព

## របាយការណ៍ទិដ្ឋភាពទូទៅ

កុម្ភៈ ២០២៥

# យុទ្ធសាស្ត្រកំណើនថ្មីរបស់ប្រទេសកម្ពុជា

# ការវាយតម្លៃកំណើនរយៈពេលមធ្យម និងវែង សម្រាប់ការអភិវឌ្ឍប្រកបដោយ ភាពធន់ បរិយាបន្ន និងចីរភាព

## របាយការណ៍ទិដ្ឋភាពទូទៅ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០២៥

**© រក្សាសិទ្ធិឆ្នាំ២០២៥ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

អគារលេខ ៥៦ ផ្លូវលេខ ៣១៥
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
លេខកូដប្រៃសនីយ៍ ១២១៥២
ទូរស័ព្ទ៖ +៨៥៥២៣ ៨៨១៧០១, ៨៨១៩១៦, ៨៨៣៦០៣
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ www.cdri.org.kh

**សេចក្តីបដិសេធ៖**

ទស្សនៈដែលបង្ហាញក្នុងរបាយការណ៍ទិដ្ឋភាពទូទៅនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងកម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ ឬក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី នោះទេ។ អ្នកនិពន្ធ គឺជាអ្នកទទួលខុសត្រូវចំពោះកំហុសដោយអចេតនាណាមួយ។

**សូមយោងឯកសារនេះថា៖**

CDRI. 2025. *Cambodia's New Growth Strategy—An Assessment of Medium and Long-term Growth for Resilient, Inclusive, and Sustainable Development: The Overview Report*, Phnom Penh: CDRI.

# មាតិកា


បញ្ជីរូបភាព និងតារាង ........ vi
សេចក្តីថ្លែងអំណរគុណ ........ vii
បញ្ជីអក្សរកាត់ ........ ix
សារគន្លឹះសំខាន់ៗ ........ ១
សង្ខេបអនុសាសន៍គន្លឹះ ........ ៤
១. សេចក្តីផ្តើម ........ ៥
២. ប្រវត្តិកំណើន និងគន្លងអភិវឌ្ឍន៍ ........ ៦
៣. ការធ្វើគំរូមាគ៌ាកំណើនរបស់កម្ពុជា ........ ៨
៤. យុទ្ធសាស្ត្រកំណើនថ្មីសម្រាប់កម្ពុជា ........ ១០
៤.១ ការពន្លឿនកំណែទម្រង់វិស័យអាទិភាពដើម្បីកំណើនរយៈពេលខ្លីទៅមធ្យម ........ ១២
៤.២ កំណែទម្រង់គ្រប់ជ្រុងជ្រោយ ដើម្បីរក្សាចីរភាពកំណើនរយៈពេលវែង ........ ១៣
៤.៣ យុទ្ធសាស្ត្រកំណើនថ្មីត្រូវតែប្រកបដោយបរិយាបន្ន និងចីរភាព ........ ១៥
៤.៤ សង្ខេបអនុសាសន៍គោលនយោបាយសំខាន់ៗ ........ ១៦
៥. ជម្នះឧបសគ្គសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ........ ១៨
៥.១ បញ្ហាប្រឈមទាក់ទងនឹងសមត្ថភាព និងគុណភាពរបស់ស្ថាប័ន ........ ១៨
៥.២ ប្រសិទ្ធភាពនៃការសម្របសម្រួលអន្តរក្រសួង/ស្ថាប័ន ........ ១៩
៥.៣ ការត្រួតពិនិត្យ និងការវាយតម្លៃ ........ ១៩
៥.៤ ការឃោសនា ការផ្សព្វផ្សាយ និងការគ្រប់គ្រងការផ្លាស់ប្តូរ ........ ១៩
៦. កំណត់គោលដៅសម្រាប់យុទ្ធសាស្ត្រចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ........ ២០
៧. សេចក្តីសន្និដ្ឋាន ........ ២០
ឯកសារសារតារ ........ ២២

# បញ្ជីរូបភាព និងតារាង

រូបភាពទី១៖ ការរួមចំណែកដល់កំណើនសេដ្ឋកិច្ច...................................................... ៨
រូបភាពទី២៖ កំណើនតាមសេណារីយ៉ូតាមដំណើរការធម្មតា និងការព្យាករការងារ ...........១០
រូបភាពទី៣៖ សេណារីយ៉ូមាគ៌ាអភិវឌ្ឍន៍.................................................................១១
រូបភាពទី៤៖ ការព្យាករកំណើន និងការងារ ដោយមានកំណែទម្រង់គ្រប់ជ្រុងជ្រោយ .........១៤
រូបភាពទី៥៖ ធាតុចេញតាមវិស័យ តាមកំណែទម្រង់គ្រប់ជ្រុងជ្រោយ ...........................១៥

តារាងទី១៖ លទ្ធផលនៃការធ្វើគំរូកំណើនសេដ្ឋកិច្ចសំខាន់ៗ.......................................១១

# សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវនេះបានធ្វើឡើងដោយមានធាតុចូលពីភាគីពាក់ព័ន្ធនានាជាច្រើន ដែលជាអ្នកមានភាពពាក់ព័ន្ធខ្ពស់លើការអភិវឌ្ឍន៍ និងវិបុលភាពនាពេលអនាគតរបស់កម្ពុជា។ ការរួមចំណែកទាំងពេលវេលា និងមតិយោបល់ក្នុងដំណើរការសិក្សា តាមរយៈសន្និសីទ សិក្ខាសាលា និងការសន្ទនាជាបុគ្គល គឺមានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងការចងក្រងខ្លឹមសារ និងអនុសាសន៍សម្រាប់របាយការណ៍នេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគីពាក់ព័ន្ធទាំងអស់ ដែលបានជួយជ្រោមជ្រែងតាំងពីពេលចាប់ផ្តើមនិងរហូតដល់ពេលបញ្ចប់គម្រោងដ៏ធំមួយនេះ។

ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងរួមគ្នាដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិទ្យាស្ថានឡូវី (Lowy Institute) នៃប្រទេសអូស្ត្រាលី។ របាយការណ៍ទិដ្ឋភាពទូទៅនេះ ត្រូវបានរៀបរៀងរួមគ្នា និងដឹកនាំដោយលោកស្រីបណ្ឌិត អេង នេត្រា នាយិកាប្រតិបត្តិនៃវិទ្យាស្ថាន CDRI ព្រមទាំងអ្នកស្រាវជ្រាវផ្សេងទៀតរួមមាន លោកបណ្ឌិត រ៉ូឡែន រ៉ាចាហ៍ (Roland Rajah) សេដ្ឋវិទូជាន់ខ្ពស់ និងជានាយកមជ្ឈមណ្ឌលអភិវឌ្ឍតណ្ឌប៉ាស៊ីហ្វិកនៃវិទ្យាស្ថានឡូវី លោកស្រីបណ្ឌិត ខេរ៉ូឡាញ ហ្យូជ (Caroline Hughes) ព្រឹទ្ធនារីរងនៃសាកលវិទ្យាល័យណត្រេដាម (University of Notre Dame) នៃសហរដ្ឋអាមេរិក កញ្ញា មុត សុមន្តធានី អ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI លោកបណ្ឌិត ឆន ឌីណា នាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មនៃវិទ្យាស្ថាន CDRI និងលោកបណ្ឌិត ជយន្ត មេនន (Jayant Menon) អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍ (ISEAS – Yusof Ishak Institute) នៃប្រទេសសិង្ហបុរី។

របាយការណ៍ទិដ្ឋភាពទូទៅនេះ ត្រូវបានគាំទ្របន្ថែមដោយឯកសារសារតារចំនួនប្រាំបួន ដែលផ្តល់នូវមូលដ្ឋានគ្រឹះគ្រប់ជ្រុងជ្រោយ សម្រាប់ការវិភាគ និងរបកគំហើញ ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ។ ឯកសារសារតារទី១ ស្តីពី*គន្លងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា៖ ការវិភាគម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០០០-២០២២* ដែលមានលោកបណ្ឌិត ហ៊ីង វុត្ថា ជាសាស្ត្រាចារ្យនៅសាលាសេដ្ឋកិច្ច និងគោលនយោបាយសាធារណៈនៃសាកលវិទ្យាល័យអាឌីឡែត (University of Adelaide) និងលោកស្រី គ្រុយ ណារិន អគ្គនាយិការងនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកនិពន្ធ។ ឯកសារសារតារទី២ ស្តីពី*បរិវត្តកម្មរចនាសម្ព័ន្ធ និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា* និពន្ធដោយលោកបណ្ឌិត ង៉ូវ ប៉េងហុយ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យណាហ្គោយ៉ា (Nagoya University) និងលោកបណ្ឌិត ចេង សារុធ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ឯកសារសារតារទី៣ និពន្ធដោយលោកបណ្ឌិត ជយន្ត មេនន ស្តីពី*ការបង្កើនបរិយាបន្ន ភាពធន់ និងចីរភាពនៃកំណើនសេដ្ឋកិច្ចនៅកម្ពុជា*។ ឯកសារសារតារទី៤ និពន្ធដោយកញ្ញា មុត សុមន្តធានី អ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ស្តីពី*ការពិនិត្យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា៖ ស្ថានភាពបច្ចុប្បន្ន និងទស្សនវិស័យអនាគតរបស់កម្ពុជា*។ ឯកសារសារតារទី៥ និពន្ធដោយលោកស្រីបណ្ឌិត អេង នេត្រា លោកស្រីបណ្ឌិត ខេរ៉ូឡាញ ហ្យូជ លោកបណ្ឌិត ជា ផល អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថាន CDRI លោកបណ្ឌិត ធិន ច័ន្ទវិទ្ធ អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថាន CDRI និងលោកស្រីបណ្ឌិត សិស៊ី គ្រូស (Cesci Cruz) សាស្ត្រាចារ្យរងដេប៉ាតឺម៉ង់វិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ា (University of California)

ស្តីពី*ការវិភាគការប្រែប្រួលអាកាសធាតុ យេនឌ័រ និងសង្គមសម្រាប់យុទ្ធសាស្ត្រកំណើនថ្មីរបស់កម្ពុជា*។ ឯកសារសារតារទី៦ និពន្ធដោយលោកស្រីបណ្ឌិត អេង នេត្រា លោកស្រីបណ្ឌិត ខេវ៉ូឡាញ ហ្សូជ និងលោកបណ្ឌិត ប៉ក់ គឹមជឿន ទីប្រឹក្សាគោលនយោបាយជាន់ខ្ពស់នៃកម្មវិធីភាពជាដៃគូកម្ពុជា អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) ស្តីពី*ការជម្នះឧបសគ្គនានាដើម្បីការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព*។ ឯកសារសារតារទី៧ និពន្ធដោយលោក ឌីន រីហ្សេទិ (Dean Rizzetti) នាយកផ្នែកគោលនយោបាយថាមពលនៃអង្គការអេនទីជីឡេបប្រចាំកម្ពុជា (Energy Lab Cambodia) ស្តីពី *ការផ្តល់ជំនាញចាំបាច់សម្រាប់អន្តរកាលថាមពលស្អាតរបស់កម្ពុជា*។ ឯកសារសារតារទី៨ និពន្ធដោយលោកស្រី ខេលី វាយអើត (Kelly Wyett) ទីប្រឹក្សាជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍វិស័យសាធារណៈនៃកម្មវិធី CAPRED ស្តីពី *មាគ៌ាពិពិធកម្មសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា*។ ជាចុងក្រោយ ឯកសារសារតារទី៩ និពន្ធដោយលោកបណ្ឌិត រ៉ូឡែន រ៉ាចាហ៍ និងលោក អាមេត អាបាយរ៉ាក់ (Ahmed Albayrak) អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលអភិវឌ្ឍតណ្ហូប៉ាស៊ីហ្វិកនៃវិទ្យាស្ថានឡូវី ស្តីពី *ការធ្វើគំរូផ្លូវទៅកាន់កំណើនប្រកបដោយគុណភាពរបស់ប្រទេសកម្ពុជា*។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកនិពន្ធទាំងអស់ សម្រាប់ឯកសារសារតារទាំងនេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) សម្រាប់ការឧបត្ថម្ភគាំទ្ររយៈពេលវែងដល់វិទ្យាស្ថាន CDRI និងការសិក្សាស្រាវជ្រាវនេះ តាមរយៈកម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) ដែលជាកម្មវិធីមួយក្នុងចំណោមកម្មវិធីសំខាន់ៗនានារបស់ក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី៕

# បញ្ជីអក្សរកាត់

| | |
|---|---|
| BAU | ព្យាករណ៍តាមដំណើរការធម្មតា |
| CAPRED | កម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| DFAT | ក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី |
| EU | សហគមន៍អឺរ៉ុប |
| FDI | ការវិនិយោគផ្ទាល់ពីបរទេស |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GFC | វិបត្តិហិរញ្ញវត្ថុសកល |
| HIC | ប្រទេសមានចំណូលខ្ពស់ |
| IDPoor Programme | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ប្រទេសកម្ពុជា |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| M&E | ការត្រួតពិនិត្យ និងវាយតម្លៃ |
| MSMEs | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| SMEs | សហគ្រាសធុនតូច និងមធ្យម |
| TFP | កត្តាផលិតភាពសរុប |
| US | សហរដ្ឋអាមេរិក |

# សារគន្លឹះសំខាន់ៗ

ការពង្រីកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាពេលថ្មីៗនេះមានលក្ខណៈល្អប្រសើរគួរឱ្យកត់សម្គាល់ ប៉ុន្តែកត្តាដែលជំរុញកំណើនសេដ្ឋកិច្ចកម្ពុជានាពេលកន្លងទៅ ទំនងជាមិនអាចរក្សាសន្ទុះដដែលនេះនៅពេលអនាគតបានឡើយ។ សន្ទុះនៃវិស័យអចលនទ្រព្យបានថយចុះ ហើយដំណើរការផ្លាស់ប្តូរទ្រង់ទ្រាយធំនៃកម្លាំងពលកម្មពីវិស័យកសិកម្មទៅវិស័យកម្មន្តសាល ជាមួយនឹងការបំប្លែងដីព្រៃទៅជាដីកសិកម្ម មិនអាចជំរុញកំណើនក្នុងអត្រាដូចមុនទៀតបានទេ។ លើសពីនេះទៀត ការប៉ះទង្គិចពីខាងក្រៅនានា ដូចជាជំងឺរាតត្បាតកូវីដ-១៩ ការកើនឡើងនៃលទ្ធិគាំពារនិយម និងការរំខានសេដ្ឋកិច្ចសកលទូលំទូលាយ បានរារាំងយ៉ាងខ្លាំងដល់ផលចំណេញនៃការអភិវឌ្ឍផ្អែកលើការនាំចេញ។ ហេតុដូច្នេះ ការរក្សាឱ្យបាននូវកំណើនឆាប់រហ័សក្នុងរយៈពេលមធ្យម និងការធានានូវភាពធន់នៃសេដ្ឋកិច្ចរយៈពេលវែង នឹងនាំមកនូវបញ្ហាប្រឈមសំខាន់ជាច្រើន។

ការដេញតាមកំណើនរយៈពេលខ្លី និងខ្លាំងក្លាពេក គឺមិនអាចធ្វើទៅបាន ហើយក៏មិនគួរឱ្យចង់បានដែរ។ ការពង្រីកសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ប៉ុន្តែមិនមានតុល្យភាព អាចនាំឱ្យមានការកើនឡើងហានិភ័យផ្នែកហិរញ្ញវត្ថុ ការសឹករេចរិលនៃបរិស្ថាន និងការកើនឡើងនៃវិសមភាពសង្គម។ ជំនួសមកវិញ ចាំបាច់ត្រូវផ្លាស់ប្តូរទិសដៅនៃការយកចិត្តទុកដាក់ទៅលើការធានា**គុណភាព**នៃការអភិវឌ្ឍ ដោយសង្កត់ធ្ងន់លើអភិបាលកិច្ចល្អ ការវិនិយោគលើមូលធនមនុស្ស បរិយាបន្នសង្គម និងចីរភាពបរិស្ថាន។ ធាតុផ្សំទាំងនេះមានសារៈសំខាន់ដូចគ្នា ឬមានសារៈសំខាន់ជាងគោលដៅចំណូលទៀតផង ដោយសារធាតុផ្សំទាំងនេះជាកត្តាកំណត់សមត្ថភាពរបស់កម្ពុជាមិនត្រឹមតែដើម្បីសម្រេចបាននូវគោលដៅរយៈពេលមធ្យមប៉ុណ្ណោះទេ ថែមទាំងជួយរក្សាគោលដៅរយៈពេលវែងរបស់កម្ពុជាផងដែរ។

ការវិភាគគោលនយោបាយគ្រប់ជ្រុងជ្រោយទៅលើសមិទ្ធផលសេដ្ឋកិច្ចរបស់កម្ពុជា ដោយមើលលើកត្តាកំណត់កំណើននានា បង្ហាញទាំងវឌ្ឍនភាព និងចន្លោះប្រហោងសំខាន់ៗ។ ចំណុចល្អគឺ សូចនាករសមិទ្ធផលរបស់កម្ពុជា ជាទូទៅមានភាពប្រសើរឡើងជាបន្តបន្ទាប់។ ទោះយ៉ាងណាក៏ដោយ វឌ្ឍនភាពនេះនៅតែមិនគ្រប់គ្រាន់ ក្នុងការកាត់បន្ថយគម្លាតជាមួយនឹងប្រទេសដែលមានសេដ្ឋកិច្ចស្រដៀងគ្នានោះទេ ដែលធ្វើឱ្យមានហានិភ័យដល់ការសម្រេចបាននូវចក្ខុវិស័យសេដ្ឋកិច្ចរបស់កម្ពុជា។ ចំណុចខ្វះខាតដែលនៅតែបន្តកើតមានឡើងនៅក្នុងបរិយាកាសធុរកិច្ច ជាពិសេសគុណភាពបទប្បញ្ញត្តិ សមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស គឺជាឧបសគ្គដ៏ធំក្នុងការបង្កើនល្បឿនកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។

ជាងនេះទៅទៀត ការងើបឡើងវិញរបស់កម្ពុជាក្រោយពីវិបត្តិជំងឺរាតត្បាតកូវីដ-១៩ ត្រូវបានរារាំងដោយបណ្តុំបញ្ហាប្រឈមជាច្រើន ដូចជាការប្រែប្រួលអាកាសធាតុ និងការចំណាយលើការរស់នៅមានការកើនឡើង និងការប៉ះទង្គិចពីកត្តាខាងក្រៅផ្សេងទៀត។ ទោះជារាជរដ្ឋាភិបាលបានផ្តល់ជំនួយដល់គ្រួសារងាយរងគ្រោះ និងសហគ្រាសខ្នាតតូចក៏ដោយ កម្ពុជាត្រូវការចាំបាច់

នូវវិធានការគោលនយោបាយដែលមានសក្តានុពល និងមានគោលដៅច្បាស់លាស់ជាងមុន ដើម្បីពង្រឹងភាពធន់ក្នុងបរិបទពិភពលោកដែលកំពុងវិវត្ត។ ការផ្លាស់ប្តូរគំរូនៃការអភិវឌ្ឍ មានភាពចាំបាច់យ៉ាងខ្លាំង៖ **ការផ្តល់អាទិភាពលើគុណភាពនៃកំណើនសេដ្ឋកិច្ច ជាជាងការគិតត្រឹមតែល្បឿននៃកំណើន** នឹងពង្រឹងស្ថិរភាពសេដ្ឋកិច្ច ជំរុញវិបុលភាពប្រកបដោយបរិយាបន្ន និងពង្រឹងស្ថាប័ននានាដែលចាំបាច់សម្រាប់កំណើនប្រកបដោយចីរភាព និងតម្លៃកាន់តែខ្ពស់។

របាយការណ៍នេះស្នើឡើងនូវ**យុទ្ធសាស្ត្រកំណើនថ្មី**មួយ ដើម្បីសម្រេចបាននូវការពង្រីកសេដ្ឋកិច្ចប្រកបដោយចីរភាព និងគុណភាពខ្ពស់ ក្នុងរយៈពេលមធ្យម និងវែង។ យុទ្ធសាស្ត្រកំណើនថ្មីនេះចែកចេញជាពីរផ្នែកគឺ៖

១) **គោលនយោបាយតាមវិស័យ៖** គោលនយោបាយទាំងនេះ គួរតែទាញយកផលប្រយោជន៍ពីនិន្នាការសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ន រួមមានការរៀបចំខ្សែច្រវាក់ផ្គត់ផ្គង់ឡើងវិញ អន្តរកាលបៃតង និងការកើនឡើងទ្រព្យធននៅទូទាំងតំបន់អាស៊ី ដើម្បីជំរុញកំណើនពីរយៈពេលខ្លីទៅមធ្យម។ វិស័យអាទិភាពនានា រួមមាន **ការកែច្នៃកសិផល គ្រឿងអេឡិចត្រូនិច សេវាកម្មដែលអាចធ្វើពាណិជ្ជកម្មបាន និងទេសចរណ៍**។ ដើម្បីសម្រេចបាននូវសក្តានុពលនៃវិស័យទាំងនេះ រាជរដ្ឋាភិបាលគួរតែផ្តោតលើការលើកកម្ពស់បរិយាកាសធុរកិច្ច ការជំរុញការអភិវឌ្ឍកម្លាំងពលកម្ម និងការដោះស្រាយឱនភាពហេដ្ឋារចនាសម្ព័ន្ធ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលនឹងបង្កើនការធ្វើសមាហរណកម្មរបស់កម្ពុជាទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល។ **គោលនយោបាយឧស្សាហកម្មទំនើប**មួយគួរចង្អុលបង្ហាញផ្លូវដល់ការវិនិយោគ ដែលធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា សំដៅកាត់បន្ថយភាពងាយរងគ្រោះដោយសារការប៉ះទង្គិចពីខាងក្រៅ។

២) **កំណែទម្រង់រចនាសម្ព័ន្ធគ្រប់ជ្រុងជ្រោយ៖** ការធានាភាពធន់នៃសេដ្ឋកិច្ច បរិយាបន្ន និងចីរភាពរយៈពេលវែង តម្រូវឱ្យមានកំណែទម្រង់ជាមូលដ្ឋាន។ **ការវិនិយោគទៅលើមូលធនមនុស្ស** ជាពិសេសក្នុងប្រព័ន្ធអប់រំ ដែលគាំទ្រការសិក្សាពេញមួយជីវិត នឹងលើកកម្ពស់ការសម្របខ្លួននៃកម្លាំងពលកម្មកម្ពុជាទៅនឹងការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យា និងសេដ្ឋកិច្ច។ ភាពបន្ទាន់ដូចគ្នានេះ គឺ**កំណែទម្រង់ស្ថាប័ន** ដែលជួយពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ កែលម្អអភិបាលកិច្ច និងលើកកម្ពស់សក្តិសិទ្ធិភាពនៃរដ្ឋបាលសាធារណៈ។ ដើម្បីជំរុញការកសាងសង្គមដែលមានភាពធន់ និងសមធម៌ ចាំបាច់ណាស់ត្រូវមានការពង្រីកប្រព័ន្ធគាំពារសង្គម ការបង្កើនលទ្ធភាពទទួលបានការថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់ និងឆ្ពោះទៅរកការគ្របដណ្តប់ជាសកល។

ខណៈដែលប្រទេសកម្ពុជាបានដាក់ចេញគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាច្រើនរួចហើយ ជាពិសេសតាមរយៈ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** បញ្ហាចំបង គឺស្ថិតលើការអនុវត្តជាក់ស្តែង។ ដើម្បីដោះស្រាយចំណុចខ្វះខាតនៃក្នុងការអនុវត្ត ចាំបាច់ត្រូវ៖

- ពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងវិស័យសាធារណៈដែលមានគុណវឌ្ឍិខ្ពស់ តាមរយៈការជ្រើសរើស ការតម្លើងឋានៈតួនាទី និងការកសាងសមត្ថភាពដោយផ្អែកលើគុណសម្បត្តិ។
- ពង្រឹងប្រព័ន្ធទិន្នន័យ ដើម្បីកែលម្អការតាក់តែងគោលនយោបាយ និងការសម្រេចចិត្ត។
- បង្កើតយន្តការអាទិភាព និងគណនេយ្យភាពច្បាស់លាស់នៅគ្រប់ស្ថាប័នសេនាធិការរដ្ឋាភិបាល។
- ពង្រឹងការចូលរួមរបស់ភាគីពាក់ព័ន្ធ តាមរយៈការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព និងយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ។

ដើម្បីពន្លឿនកំណែទម្រង់ និងដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅរក**សេដ្ឋកិច្ចដែលស្មុគស្មាញ និងប្រកបដោយចាមវន្តជាងមុន** រាជរដ្ឋាភិបាលត្រូវតែប្រតិបត្តិ**ចក្ខុវិស័យកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែងថ្មី**មួយ។ ចក្ខុវិស័យនេះត្រូវបញ្ជាក់អំពីគុណតម្លៃស្នូល គោលបំណងនៃការអភិវឌ្ឍ និងអាទិភាពគោលនយោបាយ ដែលត្រូវផ្តោតលើផ្នែកសំខាន់ៗចំនួនប្រាំមួយគឺៈ

- កំណត់គោលដៅប្រាកដនិយមសម្រាប់កំណើនសេដ្ឋកិច្ចនិងការបង្កើតការងារប្រកបដោយបរិយាបន្ន។
- ពង្រឹងតួនាទីរបស់រដ្ឋក្នុងការផ្តល់សេវាសាធារណៈ និងការគាំពារសង្គម។
- បង្កើតក្របខ័ណ្ឌសម្រាប់ចីរភាពបរិស្ថាន និងអន្តរកាលឆ្ពោះទៅសេដ្ឋកិច្ចដែលមានកាបូនទាប។
- បង្កើតយុទ្ធសាស្ត្រដើម្បីពង្រឹងការចូលរួមក្នុងសេដ្ឋកិច្ចសកលរបស់កម្ពុជា ដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍន៍ជាតិ។
- ជំរុញកំណែទម្រង់ស្ថាប័ន ដើម្បីឱ្យស្របតាមលក្ខខណ្ឌតម្រូវនៃប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។
- បង្កើតយន្តការសម្រាប់ការចូលរួមជាសាធារណៈ ក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យគោលនយោបាយ។

តាមរយៈការទទួលយកយុទ្ធសាស្ត្រមួយដែលផ្តោតលើកំណើនប្រកបដោយ**គុណភាពខ្ពស់ ចីរភាព និងបរិយាបន្ន** កម្ពុជាអាចដោះស្រាយភាពមិនប្រាកដប្រជាជាសកលបាន ខណៈបន្តឆ្ពោះទៅរកវិបុលភាពសេដ្ឋកិច្ចរយៈពេលវែង។ ការសម្រេចបាននូវ**អត្រាកំណើនជាមធ្យម ៦,៤ ភាគរយ** ក្នុងទសវត្សរ៍ខាងមុខនេះ គឺអាចធ្វើទៅបាន ក្នុងលក្ខខណ្ឌមានការរៀបចំគោលនយោបាយ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ កំណើនសេដ្ឋកិច្ចតែម្យ៉ាងមិនគ្រប់គ្រាន់ឡើយ។ តាមរយៈការជំរុញភាពធន់ ការកែលម្អអភិបាលកិច្ច និងការវិនិយោគទៅលើមូលធនមនុស្ស ប្រទេសកម្ពុជាមិនត្រឹមតែអាចធានា**ការពន្លឿន**វិបុលភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ធានាថាមាន**សមធម៌ និងភាពយូរអង្វែង**ផងដែរ។

## សង្ខេបអនុសាសន៍គន្លឹះ

### ការពន្លឿនកំណែទម្រង់តាមវិស័យ

#### ១ កំណត់គោលដៅគោលនយោបាយគាំទ្រដល់អនុឧស្សាហកម្មដែលមានសក្តានុពលខ្ពស់

- **ទាក់ទាញវិនិយោគិនបង្គោលបរទេស** ក្នុងវិស័យអាទិភាពដើម្បីពង្រឹងចង្កោមឧស្សាហកម្ម និងបង្កើនសមាហរណកម្មសកល។
- **ដោះស្រាយបញ្ហាកកស្ទះផ្នែកបទប្បញ្ញត្តិ ហេដ្ឋារចនាសម្ព័ន្ធ និងជំនាញ** តាមរយៈការចូលរួមដែលមានរចនាសម្ព័ន្ធជាមួយវិស័យឯកជន ដើម្បីកែលម្អភាពទាក់ទាញនៃការវិនិយោគ។
- **ដាក់ដំណើរការក្រុមប្រឹក្សាយោបល់ត្រួតពិនិត្យការវិនិយោគផ្ទាល់ពីបរទេស** ដើម្បីវាយតម្លៃគោលនយោបាយឧស្សាហកម្ម តំបន់សេដ្ឋកិច្ចពិសេស និងប្រព័ន្ធលើកទឹកចិត្តការវិនិយោគជាយុទ្ធសាស្ត្រ។

#### ២ ជំរុញអន្តរកាលបៃតងសម្រាប់កំណើនប្រកបដោយចីរភាព

- **ពង្រីកយន្តការផ្តល់ហិរញ្ញប្បទានបៃតង** ពិសេសសម្រាប់គម្រោងថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល។
- **គាំទ្រដល់ឧស្សាហកម្មបៃតង** តាមរយៈការលើកកម្ពស់ការទទួលយកការប្រើប្រាស់ថាមពលស្អាត បច្ចេកវិទ្យាចាប់យកកាបូន និងដំណោះស្រាយប្រសិទ្ធភាពថាមពល។
- **លើកទឹកចិត្តការអនុវត្តកសិកម្មប្រកបដោយចីរភាព** ដែលកាត់បន្ថយដានកាបូន ខណៈលើកកម្ពស់ផលិតភាព។

#### ៣ ផ្តល់អាទិភាពលើកំណែទម្រង់ដែលគាំទ្រដល់កំណើនរយៈពេលមធ្យមប្រកបដោយបរិយាបន្ន

- **ពន្លឿនការធ្វើឌីជីថលូបនីយកម្ម** ក្នុងសេវាសាធារណៈ ដើម្បីបង្កើនសក្តិសិទ្ធិភាព និងតម្លាភាព។
- **ពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅតំបន់ជនបទ** ដោយផ្តោតលើកសិករខ្នាតតូច ដើម្បីបង្កើនផលិតភាព និងការទទួលបានទីផ្សារ។
- **កែលម្អបរិយាកាសបទប្បញ្ញត្តិធុរកិច្ច** ដើម្បីសម្រួលដល់ការបង្កើតសហគ្រាសធុនមីក្រូ តូច និងមធ្យមជាផ្លូវការ បរិវត្តកម្មឌីជីថល និងលទ្ធភាពទទួលបានហិរញ្ញប្បទានដែលសមរម្យ។

### កំណែទម្រង់ជាមូលដ្ឋាន

#### ៤ កសាងមូលធនមនុស្សដើម្បីវឌ្ឍនភាពសេដ្ឋកិច្ចប្រកបដោយចីរភាព

- **កំណែទម្រង់ស៊ីជម្រៅក្នុងប្រព័ន្ធអប់រំ** ចាប់ពីមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ដោយផ្តោតសំខាន់លើភាពស្របគ្នានៃ គណនេយ្យភាព គុណភាព និងកម្លាំងពលកម្ម។
- **ពង្រីកកម្មវិធីគាំពារសង្គម** និងដាក់ចេញគោលនយោបាយគ្រួសារមេត្រី ដើម្បីទ្រទ្រង់កម្មករនិយោជិត និងសហគ្រាសធុនមីក្រូ តូច និងមធ្យម។
- **ពង្រឹងលទ្ធភាពទទួលបានការថែទាំសុខភាព** ដើម្បីធានាបានការគ្របដណ្តប់ជាសកល និងការកែលម្អគុណភាពសេវាកម្ម។

#### ៥ ពង្រឹងអភិបាលកិច្ច ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍរយៈពេលវែង

- **អនុវត្តកំណែទម្រង់គ្រប់ជ្រុងជ្រោយលើប្រព័ន្ធរដ្ឋបាលសាធារណៈ និងប្រព័ន្ធគតិយុត្តិ** ដើម្បីបង្កើនសក្តិសិទ្ធិភាព និងតម្លាភាព។
- **បង្កើនតម្លាភាព និងភាពដែលអាចព្យាករបាននៃប្រព័ន្ធពន្ធដារ** ដើម្បីបង្កើនភាពអនុលោមទៅតាមច្បាប់ និងបង្កើតប្រាក់ចំណូល។
- **បញ្ជូនបុគ្គលិកបច្ចេកទេសទៅកាន់តំបន់ជនបទ** ដើម្បីគាំទ្រសកម្មភាពសេដ្ឋកិច្ច និងធានាការផ្តល់សេវាសាធារណៈប្រកបដោយសមធម៌។

#### ៦ ជម្នះឧបសគ្គក្នុងការអនុវត្តគោលនយោបាយ

- **លើកកម្ពស់វប្បធម៌គុណាធិបតេយ្យ** តាមរយៈការជ្រើសរើសមន្ត្រីរាជការ និងការតម្លើងឋានៈតួនាទីដល់មន្ត្រីរាជការដែលមានគុណវឌ្ឍិខ្ពស់ក្នុងវិស័យសាធារណៈ។
- **ពង្រឹងការសម្របសម្រួលរវាងស្ថាប័នរដ្ឋាភិបាល** តាមរយៈការសម្រេចចិត្តដែលផ្អែកលើទិន្នន័យរឹងមាំ និងការបែងចែកទំនួលខុសត្រូវច្បាស់លាស់។
- **បង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយ និងយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ** ដើម្បីឱ្យភាគីពាក់ព័ន្ធចូលរួមក្នុងកំណែទម្រង់គោលនយោបាយ។

#### ៧ កំណត់គោលបំណងសម្រាប់ចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា

- **កំណត់គោលដៅដែលប្រាកដនិយម** សម្រាប់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារប្រកបដោយបរិយាបន្ន។
- **ពង្រឹងកម្រិតនៃសេវាសាធារណៈ និងការគាំពារសង្គម** ស្របតាមចក្ខុវិស័យប្រទេសចំណូលខ្ពស់ និងកំណត់ប្រភពចំណូលប្រកបដោយចីរភាព។
- **បង្កើតក្របខ័ណ្ឌបរិស្ថានជាតិប្រកបដោយនិរន្តរភាព** ដើម្បីផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចកាបូនទាប។
- **បង្កើតយុទ្ធសាស្ត្រសម្រាប់ការចូលរួមសេដ្ឋកិច្ចសកល** ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិ។
- **អនុវត្តកំណែទម្រង់អភិបាលកិច្ច និងកំណែទម្រង់ស្ថាប័ន** ស្របតាមលក្ខខណ្ឌតម្រូវនៃប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។
- **បង្កើតដំណើរការអភិវឌ្ឍគោលនយោបាយប្រកបដោយបរិយាបន្ន** ដែលធានាឱ្យមានការចូលរួមជាសាធារណៈក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យ។

# ១. សេចក្តីផ្តើម

ក្នុងរយៈពេលត្រឹមតែបីទសវត្សរ៍ប៉ុណ្ណោះ ប្រទេសកម្ពុជាបានប្រែក្លាយពីប្រទេសដែលមានសេដ្ឋកិច្ចខ្សោយខ្លាំងដោយសង្គ្រាម ទៅជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតមួយក្នុងពិភពលោក។ ប្រសិនបើកំណើនកម្រិតខ្ពស់នេះ នៅតែបន្តក្នុងរយៈពេលពីរទសវត្សរ៍ខាងមុខទៀតនោះ ប្រទេសកម្ពុជានឹងអាចសម្រេចគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់ខ្លួនបានយ៉ាងងាយ។

ទោះយ៉ាងណាក៏ដោយ នៅមានសំណួរសំខាន់ចំនួនពីរដែលត្រូវដោះស្រាយ។ តើប្រទេសកម្ពុជាអាចងើបឡើងវិញគ្រប់គ្រាន់ដែរឬទេ បន្ទាប់ពីវិបត្តិជំងឺរាតត្បាតកូវីដ-១៩ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន ដោយហេតុថាសណ្តាប់ធ្នាប់សេដ្ឋកិច្ចពិភពលោកកាន់តែមានភាពមិនច្បាស់លាស់? ហើយតើកំណើនសេដ្ឋកិច្ចរបស់កម្ពុជាអាចកាន់តែប្រកបដោយបរិយាបន្ន ចីរភាព និងភាពធន់នៅពេលអនាគតដែរឬទេ? របាយការណ៍នេះឆ្លើយថា “បាន” ចំពោះសំណួរទាំងពីរនេះ ដោយមានការប្តេជ្ញាចិត្តក្នុងការចាប់យកកំណែទម្រង់សំខាន់ៗ។ ការព្យាករនេះអាស្រ័យលើលក្ខខណ្ឌធ្វើកំណែទម្រង់ឱ្យលឿនជាងមុន ស្របតាមសេណារីយ៉ូយុទ្ធសាស្ត្រកំណើនថ្មី ដែលពាក់ព័ន្ធនឹងការពន្លឿនការធ្វើកំណែទម្រង់ ខណៈដែលសេណារីយ៉ូកំណែទម្រង់តាម ដំណើរការធម្មតា នឹងនាំឱ្យកំណើនមានភាពយឺតយ៉ាវ និងពន្យារពេលក្នុងការឈានទៅសម្រេចគោលដៅខាងលើនេះ។ របាយការណ៍នេះបង្ហាញពីសេណារីយ៉ូនាពេលអនាគតនានា សម្រាប់ជាយុទ្ធសាស្ត្រកំណើនថ្មី ដើម្បីទាញយកប្រយោជន៍ពីភាពជោគជ័យរបស់កម្ពុជានាពេលកន្លងមក ចាប់យកឱកាសថ្មីៗ និងដោះស្រាយចំណុចខ្សោយចំបងដែលកម្ពុជាមាន និងទទួលយកបញ្ហាប្រឈមថ្មីៗនាពេលអនាគតមួយដែលមិនច្បាស់លាស់។

របាយការណ៍ទិដ្ឋភាពទូទៅនេះ ត្រូវបានគាំទ្រដោយឯកសារសារតារចំនួនប្រាំបួន ដែលពិនិត្យលើសមិទ្ធផលកន្លងមក និងមេរៀនគោលនយោបាយ កំណត់ចំណុចខ្សោយសំខាន់ៗ និងបញ្ហាប្រឈមលេចឡើងថ្មីៗដែលនឹងកើតមាននាពេលអនាគត និងផ្តល់នូវទិដ្ឋភាពទូទៅនៃយុទ្ធសាស្ត្រកំណើនថ្មី។ របាយការណ៍នេះបង្ហាញពីកំណែទម្រង់គោលនយោបាយជាអាទិភាព ក៏ដូចជាចំណុចគន្លឹះនានា ដើម្បីជម្នះឧបសគ្គក្នុងការអនុវត្តគោលនយោបាយ។

## ២. ប្រវត្តិកំណើន និងគន្លងអភិវឌ្ឍន៍

ចាប់តាំងពីឆ្នាំ២០០០មក ប្រទេសកម្ពុជាមានអត្រាកំណើនជាង ៧ ភាគរយក្នុងមួយឆ្នាំ លើកលែងតែឆ្នាំដែលរងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសកល (GFC) និងជំងឺរាតត្បាតកូវីដ-១៩។ កម្ពុជាបានគ្រប់គ្រងជំងឺរាតត្បាតនេះប្រកបដោយប្រសិទ្ធភាព។ បន្ទាប់ពីមានកំណើនអវិជ្ជមានចំនួន ៣,១ ភាគរយ នៅឆ្នាំ២០២០ កំណើនផលិតផលក្នុងស្រុកសរុប បានស្ទុះងើបឡើងវិញដល់ចំនួន ៣,០ ភាគរយ ក្នុងឆ្នាំ២០២១ និង ៥,២ ភាគរយ ក្នុងឆ្នាំ២០២២ ដោយសារការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព និងកម្មវិធីចាក់វ៉ាក់សាំងប្រកបដោយជោគជ័យដ៏ធំធេង។ សេដ្ឋកិច្ចកម្ពុជាមានអត្រាកំណើនចំនួន ៥,២ ភាគរយ ក្នុងឆ្នាំ២០២២ និង ៥,៣ ភាគរយ នៅឆ្នាំ២០២៣ ដោយសារតម្រូវការក្នុងស្រុកបានងើបឡើងវិញ ហើយតម្រូវការខាងក្រៅកើនឡើង ដែលបានជំរុញកំណើនបន្តិចម្តងៗ ឱ្យកាន់តែជិតដល់កម្រិតមុនវិបត្តិជំងឺរាតត្បាតកូវីដ-១៩។

ទោះជាយ៉ាងណា ទស្សនវិស័យកំណើនរបស់ប្រទេសកម្ពុជាបានផ្លាស់ប្តូរយ៉ាងខ្លាំង។ កម្ពុជាត្រូវការចាំបាច់នូវកត្តាជំរុញកំណើនថ្មី ដែលទាមទារឱ្យមានគោលនយោបាយលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ច។ បរិវត្តកម្មរចនាសម្ព័ន្ធបានជំរុញឱ្យមានកំណើនក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដោយសារកម្លាំងពលកម្មបានផ្លាស់ប្តូរពីវិស័យកសិកម្ម ទៅការងារដែលមានជំនាញទាបក្នុងវិស័យកម្មន្តសាលដែលប្រើកម្លាំងពលកម្មច្រើន (មានជាអាទិ៍ វិស័យកាត់ដេរ ស្បែកជើង និងវាយនភណ្ឌ) និងវិស័យទេសចរណ៍។ ឧស្សាហកម្មទាំងនេះ ពឹងផ្អែកលើប្រាក់ឈ្នួលទាប ការអនុគ្រោះពាណិជ្ជកម្ម និងការទាក់ទាញទេសចរណ៍តែមួយកន្លែង (ប្រាសាទអង្គរវត្ត)។ មុនពេលមានជំងឺរាតត្បាត កំណើនសេដ្ឋកិច្ចកម្ពុជាមានមូលដ្ឋានតូចចង្អៀតដែលជំរុញជាចម្បងដោយការផ្លាស់ប្តូរទ្រង់ទ្រាយធំនៃកម្លាំងពលកម្មពីវិស័យកសិកម្មទៅវិស័យកម្មន្តសាល រួមជាមួយនឹងការបំប្លែងដីព្រៃទៅជាដីកសិកម្ម ក៏ដូចជាលំហូរមូលធនធំៗ ទៅក្នុងវិស័យសំណង់ និងអចលនទ្រព្យ។។ នៅពេលអនាគត កត្តាជំរុញកំណើនទាំងនេះទំនងជាពុំសូវមានសារៈសំខាន់ទៀតទេ៖

- ការផ្លាស់ប្តូររចនាសម្ព័ន្ធដំណាក់កាលដំបូង ទំនងជាបានដំណើរការទៅតាមធម្មតា។ ការប្រៀបធៀបរវាងប្រទេសផ្សេងៗបង្ហាញថា ប្រទេសកម្ពុជាបានទទួលផលប្រយោជន៍ភាគច្រើនរួចមកហើយ ពីការធ្វើពិពិធកម្មអន្តរវិស័យ ការផ្លាស់ប្តូរកម្លាំងពលកម្មពីវិស័យកសិកម្មទៅវិស័យកម្មន្តសាល ឬសេវាកម្ម។

- ការអនុគ្រោះពាណិជ្ជកម្មបានផ្តោតទៅលើសមាសភាពទំនិញនាំចេញ ក្នុងវិស័យសម្លៀកបំពាក់ និងការពឹងផ្អែកយ៉ាងខ្លាំងលើទីផ្សារមួយចំនួន ដូចជាសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលបង្កើនភាពងាយរងគ្រោះទៅនឹងតម្រូវការ និងការប៉ះទង្គិចជាក់លាក់របស់ប្រទេសទាំងនោះ។ ការអនុគ្រោះពាណិជ្ជកម្មទំនងជាប៉ះពាល់ដល់ការកំណត់គោលដៅកំណើនរបស់កម្ពុជា។

- សន្ទុះរីកចម្រើនផ្នែកសំណង់ និងអចលនទ្រព្យ បានពឹងផ្អែកយ៉ាងខ្លាំងលើការវិនិយោគលើលំនៅឋាននិងពាណិជ្ជកម្ម។ ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចនៅប្រទេសចិនបានធ្វើឱ្យសន្ទុះក្នុងវិស័យនេះធ្លាក់ចុះយ៉ាងខ្លាំង ដែលសបញ្ជាក់ឱ្យឃើញពីហានិភ័យនៃការពឹងផ្អែកខ្លាំងលើប្រទេសតែមួយ សម្រាប់ពាណិជ្ជកម្ម ជំនួយ និងការវិនិយោគ។ លើសពីនេះ សន្ទុះរីកចម្រើនផ្នែកសំណង់ និងអចលនទ្រព្យ កម្រនឹងមានចីរភាពណាស់ ហើយមិនជ្រាមជ្រែងដល់កំណើនរយៈពេលវែងនោះទេ។ នៅពេលដែលវិស័យទាំងនេះបណ្តាលឱ្យមាន "ពពុះ" នៃតម្លៃ ដែលធ្វើឱ្យសេដ្ឋកិច្ចទាំងមូលមានអស្ថិរភាព វាធ្វើឲ្យផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃវិស័យទាំងនេះ ច្រើនតែអវិជ្ជមាន។

កំណើនសេដ្ឋកិច្ចដែលបានរីកចម្រើនយ៉ាងឆាប់រហ័សកន្លងមក ក៏បាននាំឱ្យមានផលប៉ះពាល់ដល់បរិស្ថានផងដែរ ដែលជាកំណើនមិនប្រកបដោយចីរភាព។ ឧទាហរណ៍ ផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើបានធ្លាក់ចុះយ៉ាងខ្លាំង ពីជាង ៦២ ភាគរយ ក្នុងឆ្នាំ១៩៩០ មកនៅក្រោម ៤៥ ភាគរយ ក្នុងឆ្នាំ២០២១ ដោយសារការបំប្លែងដីដើម្បីប្រើប្រាស់ដែលពុំមិនការគ្រប់គ្រងត្រឹមត្រូវ និងនគរូបនីយកម្មយ៉ាងឆាប់រហ័ស ដែលបង្កើនភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុថែមទៀត។ ការបំប្លែងដីដើម្បីប្រើប្រាស់ មិនមែនជាប្រភពកំណើនប្រកបដោយចីរភាពនោះទេ។ កត្តាជំរុញកំណើនថ្មី ត្រូវតែយកចិត្តទុកដាក់ខ្ពស់លើកត្តាចីរភាព។

ប្រវត្តិកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ភាគច្រើនជាផ្នែកមួយនៃកត្តាប្រមូលមូលធនដោយការវិនិយោគសាធារណៈ និងឯកជន រួមចំណែកមួយភាគធំនៃកំណើនសេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ២០០១មក (រូបភាពទី១)។ ទោះជាយ៉ាងណា ការរួមចំណែកនៃមូលធនមនុស្ស និងកម្លាំងពលកម្ម នៅមានកម្រិតតិចតួចនៅឡើយ។ ផ្ទុយទៅវិញ ការរួមចំណែកនៃកត្តាផលិតភាពសរុប (TFP) មានការប្រែប្រួលរវាងវិជ្ជមាន និងអវិជ្ជមានក្នុងអំឡុងឆ្នាំ២០០១-២០២៣។ ខណៈដែលកត្តាកំណើនផលិតភាពសរុបនាំឱ្យមានកំណើនចំនួន ២,៧ ភាគរយ ក្នុងអំឡុងឆ្នាំ២០០១-២០០៧ កត្តាកំណើនផលិតភាពសរុបបានបង្អួសដំណើរការកំណើន ដោយធ្លាក់ចុះចំនួន ០,៨ ភាគរយ ក្នុងអំឡុងឆ្នាំ២០០៨-២០១០។ បន្ទាប់មក កត្តាកំណើនផលិតភាពសរុបមានស្ថិរភាពក្នុងអំឡុងឆ្នាំ២០១១-២០១៩ មុនពេលធ្លាក់ចុះខ្លាំងនៅឆ្នាំ២០២០-២០២៣ ដែលកំណើនសេដ្ឋកិច្ចមានត្រឹម ២,៨ ភាគរយ។ ការប្រមូលមូលធន និងបរិមាណពលកម្ម គឺជាកត្តារួមចំណែកដ៏សំខាន់ដល់កំណើនក្នុងអំឡុងឆ្នាំ២០២០-២០២៣។

កំណើនផលិតភាពនឹងត្រូវតែដើរតួនាទីកាន់តែសំខាន់ជាងមុន ក្នុងការជំរុញកំណើនសេដ្ឋកិច្ចឆ្ពោះទៅមុខ។ ការណ៍នេះនឹងតម្រូវឱ្យមានបរិវត្តកម្មរចនាសម្ព័ន្ធដំណាក់កាលថ្មី ដែលបង្ហាញពីការធ្វើពិពិធកម្មក្នុងវិស័យធំៗ (វិស័យកម្មន្តសាល និងសេវាកម្ម)។ បទពិសោធន៍អន្តរជាតិបង្ហាញថា ដំណើរការនេះមិនកើតឡើងខ្លួនឯងនោះទេ។ វាទាមទារឱ្យមានការសម្របសម្រួលយ៉ាងសកម្មពីរដ្ឋាភិបាល និងកំណែទម្រង់សេដ្ឋកិច្ច ជាពិសេសទាក់ទងនឹងមូលធនមនុស្ស និងបរិយាកាសធុរកិច្ចដែលអំណោយផល។

រូបភាពទី១៖ ការរួមចំណែកដល់កំណើនសេដ្ឋកិច្ច




ប្រភព៖ ការប៉ាន់ស្មានរបស់អ្នកនិពន្ធផ្អែកលើគណនេយ្យជាតិ IMF, Penn World Tables

## ៣. ការធ្វើគំរូមាគ៌ាកំណើនរបស់កម្ពុជា

ការធ្វើគំរូដែលប្រើសម្រាប់ការសិក្សានេះ ផ្ដោតលើការវិភាគកត្តាជំរុញកំណើនសេដ្ឋកិច្ចសំខាន់ៗ និងប្រើគំរូនេះជាមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីទស្សនវិស័យសេដ្ឋកិច្ចកម្ពុជានាពេលអនាគត។ ការសិក្សានេះបានប្រើវិធីសាស្ត្រចំនួនពីរ ដើម្បីរៀបចំគំរូកំណើនសេដ្ឋកិច្ចកម្ពុជានាពេលអនាគត។ ទី១ យើងប្រើគំរូនីអូក្លាស៊ិក (neoclassical model) បែបប្រពៃណីដែលលើកឡើងថា កំណើនសេដ្ឋកិច្ចគឺអាស្រ័យទៅលើការកើនឡើងនៃចំនួនកម្មករ ការកែលម្អមូលធនមនុស្ស ការវិនិយោគមូលធនឯកជន និងសាធារណៈ ព្រមទាំងការបង្កើនកត្តាផលិតភាពសរុប។ តាមការបកស្រាយបែបសាមញ្ញ កត្តាផលិតភាពសរុបគឺសំដៅទៅលើប្រសិទ្ធភាពទីផ្សារ ចំណេះដឹង និងបច្ចេកវិទ្យា និងគុណភាពស្ថាប័ន។ ទី២ យើងប្រើគំរូវិធីសាស្ត្រតាមវិស័យ (sectoral approach) (បរិវត្តកម្មរចនាសម្ព័ន្ធ) ដែលលើកឡើងថា កំណើនសេដ្ឋកិច្ចអាស្រ័យលើការកើនឡើងនៃកម្លាំងពលកម្ម បម្លាស់ទីកម្មករពីវិស័យមានផលិតភាពកម្រិតទាប ទៅវិស័យមានផលិតភាពកម្រិតខ្ពស់ (ឧទាហរណ៍ ពីកសិកម្ម ទៅកម្មន្តសាល) និងការកើនឡើងនៃផលិតភាពនៃពលកម្មដែលមានតម្លៃបន្ថែម នៅក្នុងវិស័យនីមួយៗ (រួមទាំងតាមរយៈការធ្វើវិសិដ្ឋកម្មឧស្សាហកម្ម)។ ការប្រើគំរូទាំងពីរនេះរួមគ្នាបានផ្ដល់នូវការយល់ដឹងស៊ី

ជម្រៅផ្សេងៗគ្នា លើទស្សនវិស័យនៃកំណើនសេដ្ឋកិច្ចកម្ពុជានាពេលអនាគត និងធ្វើឱ្យប្រសើរឡើងនូវលំហាត់សិក្សាស៊ីជម្រៅនេះ ដោយយកលទ្ធផលជាមធ្យមនៃគំរូទាំងពីរ ដើម្បីបង្កើតការព្យាករសេណារីយ៉ូនីមួយៗ។

វិធីសាស្ត្រនៃការធ្វើគំរូទាំងពីរនេះ បង្ហាញពីកំណើនធ្លាក់ចុះនាពេលអនាគត យោងតាមសេណារីយ៉ូតាមដំណើរការធម្មតា។

**គំរូនីអូក្លាសិក៖** ការវិនិយោគឯកជននឹងចុះខ្សោយជាងមុន ដោយសារសន្ទុះរីកចម្រើននៃវិស័យអចលនទ្រព្យធ្លាក់ចុះខ្លាំង បំណុលសាជីវកម្មកើនឡើង និងធនាគារប្រឈមនឹងតណទានមិនដំណើរការកម្រិតខ្ពស់។ ការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធមានកម្រិតទាបជាងមុន ដោយសារលក្ខខណ្ឌសារពើពន្ធកាន់តែតឹងរ៉ឹង និងគម្រោងដែលទទួលមូលនិធិពីដៃគូអភិវឌ្ឍន៍អន្តរជាតិកាន់តែតិចជាងមុន។ តម្រូវការនៃការវិនិយោគលើការសម្របខ្លួន បង្កើនការចំណាយលើការវិនិយោគ។ ជារួម គេព្យាករថា ការវិនិយោគសរុបនឹងត្រលប់ទៅរកកម្រិតមធ្យមប្រមាណ ២៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប រវាងឆ្នាំ២០០០-២០១៩ ដែលទាបជាងការវិនិយោគកម្រិតខ្ពស់បំផុតថ្មីៗនេះ ដែលមានប្រមាណ ៣៨ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២២។ ការកែលម្អមូលធនមនុស្ស ដើរតាមនិន្នាការចាស់ឆ្នាំ២០០០-២០១៩ រីឯកំណើនកត្តាផលិតភាពសរុប មានភាពយឺតយ៉ាវបន្តិចនៅក្នុងរយៈពេលវែង។ មូលហេតុចម្បងនៃកំណើនយឺតនៅក្នុងក្របខ័ណ្ឌនីអូក្លាសិក គឺការធ្លាក់ចុះខ្លាំងនៃការរួមចំណែកពីការប្រមូលមូលធននាពេលអនាគត ដោយសារអត្រាវិនិយោគសាធារណៈ និងឯកជនទាបផង និងដោយសារការថយចុះផលចំណេញ បន្ទាប់ពីមានការវិនិយោគខ្ពស់ជាច្រើនទសវត្សរ៍ (រូបភាពទី២ក)។

**សេណារីយ៉ូទស្សនវិស័យតាមវិស័យ៖** ការធ្លាក់ចុះនៃសន្ទុះនៃវិស័យអចលនទ្រព្យតែមួយមុខ បានកាត់បន្ថយកំណើននាពេលអនាគតចំនួន ១,២ ឯកតាភាគរយ បើធៀបនឹងរយៈពេលមុនជំងឺរាតត្បាតកូវីដ-១៩។ ការរួមចំណែករបស់វិស័យកម្មន្តសាលក្នុងការបង្កើតការងារសរុប បាននៅទ្រឹងត្រឹមប្រមាណ ១៦ ភាគរយ ហើយត្រូវបានគេព្យាករថា នឹងនៅតែស្ថិតក្នុងកម្រិតនេះក្នុងរយៈពេលមួយទសវត្សរ៍ទៀត មុននឹងធ្លាក់ចុះបន្តទៀត ដោយសារសេដ្ឋកិច្ចប្រទេសកម្ពុជា នឹងមានភាពរីកចម្រើន ហើយតម្លៃពលកម្មនឹងកើនឡើង។ បច្ចុប្បន្ននេះ កំណើនផលិតភាពមានតិចតួចក្នុងវិស័យកម្មន្តសាល ដោយសារការធ្វើវិសិដ្ឋកម្មឧស្សាហកម្មមានដំណើរការយឺតយ៉ាវ។ នាពេលថ្មីៗនេះ ការបង្កើតការងារមិនមែនកសិកម្ម គឺភាគច្រើននៅក្នុងវិស័យសំណង់ និងសេវាកម្មបែបប្រពៃណី (ឧទាហរណ៍ ពាណិជ្ជកម្ម និងបដិសណ្ឋារកិច្ច)។ កំណើនក្នុងវិស័យសំណង់ត្រូវបានបញ្ចប់ រីឯវិស័យសេវាកម្មនឹងបន្តមានកំណើន ប៉ុន្តែអត្ថប្រយោជន៍នៃផលិតភាពក្នុងវិស័យនេះមានកម្រិតទាប។ ជារួម ខ្លឹមសារគន្លឹះនៃទស្សនបរិវត្តកម្មរចនាសម្ព័ន្ធគឺថាការងារនៅក្នុងប្រទេសកម្ពុជាលែងជាឧស្សាហនីយកម្មឆាប់រហ័សទៀតហើយ ផ្ទុយទៅវិញវិស័យសេវាកម្មកាន់តែគ្របដណ្តប់ខ្លាំងទៅលើការបង្កើតការងារ (រូបភាពទី២ខ) ប៉ុន្តែសមិទ្ធផលផលិតភាពនៃពលកម្មនៅមានសភាពទន់ខ្សោយ។

រូបភាពទី២៖ កំណើនតាមសេណារីយ៉ូតាមដំណើរការធម្មតា និងការព្យាករការងារ




ប្រភព៖ ការព្យាកររបស់អ្នកនិពន្ធ ផ្អែកលើស្ថិតិគណនេយ្យជាតិ

# ៤. យុទ្ធសាស្ត្រកំណើនថ្មីសម្រាប់កម្ពុជា

យុទ្ធសាស្ត្រកំណើនមានស្រាប់របស់កម្ពុជា ដែលអាស្រ័យលើស្ថិរភាពនយោបាយ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏វ័យឆ្លាត និងការបើកចំហសេដ្ឋកិច្ច បានធ្វើឱ្យកម្ពុជាអាចទាញយកផលប្រយោជន៍ពីឧត្តមភាពប្រកួតប្រជែងសំខាន់ៗរបស់ខ្លួន ដូចជាកម្លាំងពលកម្មដែលមានតម្លៃទាប សម្បត្តិទេសចរណ៍លំដាប់ពិភពលោក និងទីតាំងភូមិសាស្ត្រដែលមានសក្តានុពលនៅក្នុងតំបន់អាស៊ីបូព៌ា។ ទោះជាយ៉ាងណាក៏ដោយ មូលដ្ឋានគ្រឹះទាំងនេះតែម្យ៉ាងលែងគ្រប់គ្រាន់ទៀតហើយ។ ការធ្វើគំរូនៃសេណារីយ៉ូដែលបានពិភាក្សាខាងលើ បង្ហាញថាបើតាមការព្យាករក្នុងលក្ខខណ្ឌតាមដំណើរការធម្មតា កំណើនសេដ្ឋកិច្ចនឹងមានភាពយឺតយ៉ាវជាង នៅមុនពេលជំងឺរាតត្បាតកូវីដ-១៩។ នៅចន្លោះឆ្នាំ២០២៤-២០៣០ សេណារីយ៉ូតាមដំណើរការធម្មតានេះអាចមើលឃើញកំណើនសេដ្ឋកិច្ចជាប់គាំងនៅប្រហែល ៥,៤ ភាគរយ ក្នុងមួយឆ្នាំ ស្រដៀងគ្នានឹងល្បឿននាពេលបច្ចុប្បន្ន។ តាមបទដ្ឋានអន្តរជាតិ កម្ពុជានឹងនៅតែជាប្រទេសមានសេដ្ឋកិច្ចលូតលាស់លឿនក្នុងល្បឿននេះ តែទោះជាយ៉ាងណា វានៅតែទាបជាងអត្រាវឌ្ឍនភាពដែលកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាចង់បាន។ សំខាន់ជាងនេះទៅទៀត ក្នុងរយៈពេលវែង ការខាតបង់ដោយសារការបន្តអនុវត្តតាមដំណើរការធម្មតា នឹងកាន់តែខ្ពស់ជាងនេះ ហើយអាចនឹងនាំឱ្យកម្ពុជាជាប់គាំងក្នុងអន្ទាក់ប្រទេសមានចំណូលមធ្យម។ រូបភាពទី៣ និងតារាងទី១ ខាងក្រោមសង្ខេបលទ្ធផលសំខាន់ៗនៃការធ្វើគំរូកំណើនដែលបានប្រើសម្រាប់របាយការណ៍នេះ។

## រូបភាពទី៣៖ សេណារីយ៉ូមាគ៌ាអភិវឌ្ឍន៍




ប្រភព៖ ការព្យាកររបស់អ្នកនិពន្ធ និងស្ថិតិគណនេយ្យជាតិ

## តារាងទី១៖ លទ្ធផលនៃការធ្វើគំរូកំណើនសេដ្ឋកិច្ចសំខាន់ៗ

| **សេណារីយ៉ូ** | **ការព្យាករកំណើនសេដ្ឋកិច្ច** | | |
|---|---|---|---|
| | 2024-2030 | 2031-2040 | 2041-2050 |
| ១. ការព្យាករតាមដំណើរការធម្មតា | 5.4% | 4.3% | 3.4% |
| ២. មានតែការពន្លឿនគោលនយោបាយតាមវិស័យ | 6.4% | 5.1% | 3.1% |
| ៣. ជាមួយកំណែទម្រង់គ្រប់ជ្រុងជ្រោយ | 6.4% | 6.3% | 5.3% |

ប្រភព៖ ការព្យាកររបស់អ្នកនិពន្ធ និងស្ថិតិគណនេយ្យជាតិ

ជាការឆ្លើយតប របាយការណ៍នេះផ្តល់អនុសាសន៍ឱ្យកម្ពុជាប្រកាន់យកយុទ្ធសាស្ត្រកំណើនថ្មី ដែលផ្តោតលើកិច្ចខិតខំប្រឹងប្រែងគោលនយោបាយរបស់រដ្ឋាភិបាលក្នុងទិដ្ឋភាពចំនួនពីរ។ ទិដ្ឋភាពទី១ និងជាបន្ទាន់ គឺផ្តោតលើ**ការពន្លឿនទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យមរបស់កម្ពុជា តាមរយៈកិច្ចខិតខំប្រឹងប្រែងគោលនយោបាយលើវិស័យអាទិភាព**។ ចំណុចនេះត្រូវផ្តោតលើផ្នែកតូចៗនៃឧស្សាហកម្មដែលមានសក្តានុពលខ្ពស់ (ជាពិសេស ផ្នែកអេឡិចត្រូនិច ការកែច្នៃកសិផល សេវាកម្មដែលអាចធ្វើពាណិជ្ជកម្មបាន និងទេសចរណ៍) រួមទាំងគោលនយោបាយគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម (SMEs) និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ធាតុផ្សំនៃយុទ្ធសាស្ត្រនេះទទួលស្គាល់ថា ជាធម្មតាកំណើនឆាប់រហ័ស គឺពឹងផ្អែកលើការសម្រេចបានសមិទ្ធផលរឹងមាំ នៅក្នុងវិស័យសំខាន់ៗមួយចំនួន ខណៈការសម្រេចបាននូវបរិយាបន្ន ទាមទារឱ្យ

កំណើនសេដ្ឋកិច្ចបានទៅដល់កម្មករភាគច្រើនដែលមានប្រាក់ចំណូលទាប នៅក្នុងវិស័យសេវាកម្មបែបប្រពៃណី និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ប្រសិនបើកម្ពុជាអាចធ្វើបានជោគជ័យដូចអ្វីដែលបានលើកឡើងនេះ កំណើនសេដ្ឋកិច្ចកម្ពុជានឹងរីកចម្រើនលឿនជាងមុន ជាមធ្យមប្រមាណ ៦,៤ ភាគរយ ក្នុងមួយឆ្នាំ ក្នុងរយៈពេលប៉ុន្មានឆ្នាំទៅមុខទៀតនេះ។

ធាតុផ្សំទី២នៃយុទ្ធសាស្ត្រជាអនុសាសន៍ទទួលស្គាល់ថា **កំណែទម្រង់គ្រប់ជ្រុងជ្រោយមានភាពចាំបាច់ណាស់ ក្នុងការរក្សាចីរភាពនៃកំណើនឆាប់រហ័សក្នុងរយៈពេលវែង។** ការផ្តោតសំខាន់ត្រង់ចំណុចនេះ គឺការអភិវឌ្ឍមូលធនមនុស្ស (ការអប់រំ និងសុខាភិបាល) និងការកែលម្អគុណភាពស្ថាប័ន (ឬអភិបាលកិច្ច)។ ធាតុផ្សំទី៣នៃយុទ្ធសាស្ត្រកំណើនថ្មី គឺថាកម្ពុជា **ទទួលស្គាល់ដោយម៉ឺងម៉ាត់នូវ បរិយាបន្ន និងការងារដែលមានគុណភាព ក៏ដូចជាការគិតគូរដល់អាទិភាពគន្លឹះនៃនិរន្តរភាពបរិស្ថាន និងភាពធន់នៃសង្គម។** យើងត្រូវទទួលស្គាល់ថា កំណែទម្រង់នៅក្នុងវិស័យទាំងនេះត្រូវការពេលវេលាដើម្បីទទួលបានផ្លែផ្កា។ ប៉ុន្តែបើគ្មានវឌ្ឍនភាពនៃមូលដ្ឋានគ្រឹះសំខាន់ៗទាំងនេះទេ កំណើននឹងមិនអាចទៅមុខបានលឿនឡើយ។ ផ្ទុយទៅវិញ បើវិស័យទាំងនេះបានទទួលជោគជ័យ ប្រទេសកម្ពុជាត្រូវបានព្យាករថា នឹងសម្រេចបានកំណើនឆាប់រហ័ស និងទូលំទូលាយ ដែលអាចរក្សាកំណើនក្នុងកម្រិត ៥-៦ ភាគរយ នៅទសវត្សរ៍បន្តបន្ទាប់។

## ៤.១ ការពន្លឿនកំណែទម្រង់វិស័យអាទិភាពដើម្បីកំណើនរយៈពេលខ្លីទៅមធ្យម

ប្រទេសកម្ពុជាមិនមានពេលច្រើនទៀតទេ។ ការពន្យារពេលមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់វិបុលភាពជាតិដែលសម្រេចបានកន្លងមកប៉ុណ្ណោះទេ ថែមទាំងប្រថុយនឹងការបាត់បង់ឱកាសសំខាន់ៗសម្រាប់កំណើនសេដ្ឋកិច្ច ហើយអាចបង្កើនភាពងាយរងគ្រោះខាងសេដ្ឋកិច្ចនាពេលអនាគតថែមទៀត។ មធ្យោបាយល្អបំផុតដើម្បីសម្រេចបានកំណើនលឿនជាងមុន ក្នុងរយៈពេលមធ្យមគឺការពន្លឿនកិច្ចខិតខំប្រឹងប្រែងផ្នែកគោលនយោបាយលើឧស្សាហកម្មគោលដៅមួយចំនួន ដែលមានសក្តានុពលខ្ពស់ ហើយផ្តល់ការគាំទ្រដល់បរិយាបន្នសង្គមផងដែរ។

ស្ថានភាពពិភពលោក និងតំបន់នាពេលបច្ចុប្បន្នផ្តល់កាលានុវត្តភាពសំខាន់ៗចំនួន ៣ សម្រាប់គោលនយោបាយតាមវិស័យគឺ៖ ១) ការកំណត់រចនាសម្ព័ន្ធបណ្តាញផលិតកម្មសកលឡើងវិញ ដោយសារខ្សែច្រវាក់ផ្គត់ផ្គង់ និងការបន្តចាកចេញនៃវិនិយោគទុនពីប្រទេសចិន ២) អន្តរកម្មបៃតង និង ៣) ការបន្តរីកចម្រើននៃសេដ្ឋកិច្ច អ្នកប្រើប្រាស់ និងធុរកិច្ចនៅក្នុងតំបន់អាស៊ី។ នេះជាកាលានុវត្តភាពដ៏កម្រដែលមានតែម្តងក្នុងមួយជំនាន់ ដោយផ្តល់ផលប្រយោជន៍ដ៏ធំបំផុត សម្រាប់ប្រទេសទាំងឡាយណាដែលរួសរាន់ចាប់យកឱកាសទាំងនេះបានទាន់ពេលវេលា។ ការទទួលផលពីឥទ្ធិពលជាចង្កោម និងបណ្តាញទាំងនេះ អាចជួយពង្រឹង និងកសាងភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងឧស្សាហកម្មថ្មីៗនាពេលអនាគត។

ក្នុងរយៈពេលខ្លីទៅមធ្យម កំណើនសេដ្ឋកិច្ចឆាប់រហ័សអាចសម្រេចបាន ដោយការផ្លាស់ប្តូរសេដ្ឋកិច្ច ឆ្ពោះទៅរកឧស្សាហកម្មសំខាន់ៗមួយចំនួនដែលមានសមិទ្ធផលខ្ពស់ ដែលអាចបង្កើតផលចំណេញផលិតភាពបានច្រើន ដូចដែលឧស្សាហកម្មកាត់ដេរនៅកម្ពុជាសម្រេចបាននាពេល

កន្លងមក។ បរិវត្តកម្មរចនាសម្ព័ន្ធត្រូវវិវត្តដល់ដំណាក់កាលថ្មីមួយ ដោយពង្រីកវិស័យកម្មន្តសាលតាមរយៈការធ្វើពិពិធកម្មទៅក្នុងអនុឧស្សាហកម្មថ្មីៗដែលមានសក្តានុពល។

ឧស្សាហកម្មកែច្នៃកសិផល និងគ្រឿងបង្គុំអេឡិចត្រូនិក គឺជាអនុឧស្សាហកម្មកម្មន្តសាលដែលអាចនឹងមានសក្តានុពលខ្ពស់បំផុត ដែលមិនត្រឹមតែជួយឱ្យកម្ពុជាឈានទៅរកសកម្មភាពមានតម្លៃបន្ថែមខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែវាជាអនុឧស្សាហកម្មដែលអាចធ្វើទៅបាន ដោយពឹងផ្អែកលើសមត្ថភាព និងឧត្តមភាពប្រកួតប្រជែងនាពេលបច្ចុប្បន្នរបស់កម្ពុជា (ពោលគឺនៅក្នុងវិស័យកម្មន្តសាលគ្រឹះដែលប្រើកម្លាំងពលកម្មច្រើន) ហើយក៏ជាមូលដ្ឋានគ្រឹះសម្រាប់វិសិដ្ឋកម្មឧស្សាហកម្មនាពេលអនាគតក្នុងរយៈពេលវែង (ឧទាហរណ៍ វិស័យគ្រឿងម៉ាស៊ីន និងរថយន្ត)។ ជាទូទៅ នេះជាមាគ៌ាដែលប្រទេសនៅអាស៊ីផ្សេងទៀតអនុវត្តបានជោគជ័យ និងជាមាគ៌ាដែលកម្ពុជាកំពុងស្វែងរកដើម្បីយកមកអនុវត្តតាម រួមមានប្រទេសវៀតណាម និងចិន។

ជាមួយនឹងជោគជ័យនៃការពន្លឿនកិច្ចខិតខំប្រឹងប្រែងខាងគោលនយោបាយតាមវិស័យ គេមើលឃើញថា ប្រទេសកម្ពុជាអាចសម្រេចបានកំណើនរហូតដល់ ៦ ភាគរយ ក្នុងទសវត្សរ៍ខាងមុខនេះ។ ការណ៍នេះនឹងបង្កើតការងារមិនមែនកសិកម្មបានកាន់តែច្រើន (រូបភាពទី៤ខ)។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើតការងារមិនមែនកសិកម្មមួយចំនួនធំ ទំនងនៅតែមានក្នុងវិស័យសេវាកម្ម ជាពិសេសសម្រាប់កម្មករដែលមានជំនាញទាប។ វិស័យទេសចរណ៍ក៏នៅតែអាចរក្សាបានសក្តានុពលកំណើន ជាពិសេសដោយសារប្រទេសកម្ពុជានៅជិតប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើននៅតំបន់អាស៊ីដែលសម្បូរណ៍អ្នកមានចំណូលមធ្យម ហើយវិស័យទេសចរណ៍ជាឧស្សាហកម្មដែលពឹងផ្អែកខ្លាំងលើសេវាកម្ម។ ហេតុនេះ គោលនយោបាយដែលសំដៅជំរុញកំណើនផលិតភាពក្នុងវិស័យសេវាកម្មបែបប្រពៃណីដើម្បីស្របនឹងប្រទេសមានសេដ្ឋកិច្ចខ្ពស់ អាចរួមចំណែកប្រកបដោយអត្ថន័យដល់កំណើនខ្លាំងជាងមុន និងប្រកបដោយបរិយាបន្ន។

## ៤.២ កំណែទម្រង់គ្រប់ជ្រុងជ្រោយ ដើម្បីរក្សាចីរភាពកំណើនរយៈពេលវែង

ក្នុងពេលជាមួយគ្នានេះ កម្ពុជាត្រូវពន្លឿនកិច្ចខិតខំប្រឹងប្រែងគិតគូរដល់អាទិភាពកំណែទម្រង់រយៈពេលវែងសំខាន់ៗ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការរក្សាចីរភាពវឌ្ឍនភាព។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនទាន់ធ្វើឱ្យមានវឌ្ឍនភាពគ្រប់គ្រាន់ ក្នុងវិស័យគោលនយោបាយសំខាន់ៗមួយចំនួន ដែលមានសារៈសំខាន់សម្រាប់ការរក្សាចីរភាពកំណើនសេដ្ឋកិច្ចឆាប់រហ័សក្នុងរយៈពេលវែងនៅឡើយ។ ជាទូទៅ វិស័យទាំងនេះទាក់ទងនឹងការពង្រឹងមូលធនមនុស្ស និងគុណភាពស្ថាប័ន ព្រមទាំងភាពធន់នៃសង្គម និងចីរភាពបរិស្ថាន។ របាយការណ៍នេះ បានធ្វើការវិភាគលើចន្លោះប្រហោងនៃគោលនយោបាយ ដោយប្រៀបធៀបប្រទេសកម្ពុជាទៅនឹងប្រទេសដែលមានស្ថានភាពស្រដៀងគ្នានាពេលបច្ចុប្បន្ន និងពេលអនាគត ក្នុងវិស័យគន្លឹះមួយចំនួន។ ការប្រៀបធៀបនេះបង្ហាញថា កម្ពុជាទទួលបានសមិទ្ធផលល្អក្នុងវិស័យគោលនយោបាយ ដែលផ្សាភ្ជាប់ខ្លាំងនឹងការសម្រេចបាននូវបរិវត្តកម្មរចនាសម្ព័ន្ធ (ពោលគឺកំណើនដែលជំរុញដោយវិស័យមានកំណត់មួយចំនួន) ប៉ុន្តែបើធៀបនឹងវិស័យផ្សេងទៀតដែលសំខាន់សម្រាប់កំណើនរយៈពេលវែង កម្ពុជាពុំសូវមានវឌ្ឍភាពគ្រប់គ្រាន់នោះទេ។ ជាឧទាហរណ៍

បើធៀបនឹងប្រទេសមួយចំនួន កម្ពុជាកំពុងមានវឌ្ឍនភាពលើការបង្រួមគម្លាតជាមួយប្រទេសមានប្រាក់ចំណូលខ្ពស់ ទាក់ទងនឹងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ការបើកចំហចំពោះពាណិជ្ជកម្ម និងការវិនិយោគ ស្ថិរភាពនយោបាយ និងប្រសិទ្ធភាពរបស់រដ្ឋាភិបាល។ ទាក់ទងនឹងមូលធនមនុស្ស កម្ពុជាកំពុងមានការរីកចម្រើនផ្នែកបរិមាណ (ឱកាសទទួលបានការអប់រំ) ប៉ុន្តែខាងផ្នែកគុណភាពនៅមានគម្លាតធំ ហើយហាក់មិនមានភាពប្រសើរឡើងស្របតាមតម្រូវការនោះទេ។ បរិយាកាសធុរកិច្ចរបស់កម្ពុជាក៏នៅមានកម្រិត ដោយមានបញ្ហាប្រឈមលើដំណើរការផ្នែកភស្តុភារ គុណភាពបទប្បញ្ញត្តិ និងការរឹតត្បិតផ្នែកឌីជីថល។ ដូច្នេះ វាតម្រូវឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់លើរបៀបវារៈកំណែទម្រង់បទប្បញ្ញត្តិ ដើម្បីគាំទ្រដល់ការប្រកួតប្រជែងផ្នែកឧស្សាហកម្មរបស់កម្ពុជា។

រូបភាពទី៤៖ ការព្យាករកំណើន និងការងារ ដោយមានកំណែទម្រង់គ្រប់ជ្រុងជ្រោយ




ប្រភព៖ ការព្យាកររបស់អ្នកនិពន្ធ និងស្ថិតិគណនេយ្យជាតិ

កំណែទម្រង់គ្រប់ជ្រុងជ្រោយ គួរផ្តោតលើការអភិវឌ្ឍមូលធនមនុស្ស និងអភិបាលកិច្ច ហើយទន្ទឹមនឹងនោះ ក៏ត្រូវគិតគូរពីអាទិភាពនៃភាពធន់ផ្នែកបរិស្ថាន និងសង្គមផងដែរ។ ដោយមានភាពជោគជ័យលើវិស័យទាំងនេះ កម្ពុជាត្រូវបានគេព្យាករថានឹងសម្រេចបាននូវកំណើនឆាប់រហ័ស និងទូលំទូលាយ នៅកម្រិត ៥-៦ ភាគរយក្នុងប៉ុន្មានទសវត្សរ៍ខាងមុខនេះ។

ប្រសិនបើកម្ពុជាទទួលបានជោគជ័យ ក្នុងការកែលម្អមូលដ្ឋានគ្រឹះរយៈពេលវែងរបស់ខ្លួន នោះកម្ពុជាអាចនឹងសម្រេចបាននូវកំណើនប្រកបដោយចីរភាព និងទូលំទូលាយ។ នៅក្នុងសេណារីយ៉ូកំណែទម្រង់គ្រប់ជ្រុងជ្រោយដែលជាការធ្វើគំរូក្នុងការសិក្សានេះ កំណើននឹងរក្សាចីរភាពក្នុងរង្វង់ ៥-៦ ភាគរយ ក្នុងរយៈពេលវែង ជាមួយនឹងឧស្សាហូបនីយកម្មកាន់តែខ្លាំងឡើង ក៏ដូចជាការធ្វើពិពិធកម្មបន្តិចម្តងៗលើសេវាកម្មឌីជីថល និងធុរកិច្ចទំនើប (រូបភាពទី៥)។

រូបភាពទី៥៖ ធាតុចេញតាមវិស័យ តាមកំណែទម្រង់គ្រប់ជ្រុងជ្រោយ




ប្រភព៖ អ្នកនិពន្ធ ដោយផ្អែកលើសូចនាករអភិបាលកិច្ចទូទាំងពិភពលោក (Worldwide Governance Indicators) និងស្ថិតិគណនេយ្យជាតិ

## ៤.៣ យុទ្ធសាស្ត្រកំណើនថ្មីត្រូវតែប្រកបដោយបរិយាបន្ន និងចីរភាព

បន្ថែមពីលើយុទ្ធសាស្ត្រកំណើនទាំងពីរខាងលើ ដែលផ្តោតលើការពន្លឿនកិច្ចខិតខំប្រឹងប្រែងផ្នែកនយោបាយតាមវិស័យ និងយុទ្ធសាស្ត្រកំណែទម្រង់ដែលគ្រប់ជ្រុងជ្រោយជាងមុន កម្ពុជាត្រូវតែចាប់យកការអភិវឌ្ឍប្រកបដោយបរិយាបន្ន ដែលមានចីរភាពនិងភាពធន់ផងដែរ។ ដូចនេះ កម្ពុជាអាចរក្សាកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៥-៦ ភាគរយក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ខាងមុខនេះ ហើយក៏អាចឈានដល់គោលដៅចុងក្រោយនៃកំណើននាពេលអនាគតរបស់ខ្លួន។

ផែនការយុទ្ធសាស្ត្ររយៈពេលវែង ដូចជា យុទ្ធសាស្ត្របញ្ចកោណ និងគោលនយោបាយសេដ្ឋកិច្ចដែលជាមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រទាំងអស់នេះ មានគោលបំណងដោយផ្ទាល់ ឬដោយប្រយោល គាំទ្រដល់កំណើនសេដ្ឋកិច្ចបៃតង ប្រកបដោយបរិយាបន្ន ចីរភាព និងភាពធន់។ កំណើនបៃតងចាំបាច់ត្រូវឆ្ពោះទៅរកការកាត់បន្ថយ និងការសម្របខ្លួននឹងការប្រែប្រួលអាកាសធាតុ ដោយជៀសវាងការធ្វើឱ្យរេចរិលបរិស្ថាននៅកម្រិតមូលដ្ឋាន។ កំណើនប្រកបដោយបរិយាបន្នត្រូវតែបង្កើតការងារសមរម្យ និងប្រកបដោយចីរភាព ក្នុងវិស័យកម្មន្តសាល និងវិស័យសេវាកម្ម ទន្ទឹមនឹងផ្តល់ផលចំណេញសមរម្យ និងប្រកបដោយចីរភាព សម្រាប់បុគ្គលស្វ័យនិយោជន៍ ក្នុងវិស័យកសិកម្ម ឬនៅក្នុងសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) នៅគ្រប់វិស័យនានា ទាំងសេដ្ឋកិច្ចក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ។ កំណើនប្រភេទនេះ គឺពីថ្នាក់ក្រោមឡើងលើ ដោយចាប់ផ្តើមពីការពង្រឹងសមត្ថភាពប្រជាពលរដ្ឋដែលគ្រប់អាយុធ្វើការ តាមរយៈការអប់រំ និងការអភិវឌ្ឍជំនាញ និងតាមរយៈឱកាសស្មើគ្នាក្នុងការចូលរួមជំរុញកំណើនសេដ្ឋកិច្ច។ ការងារបែបនេះត្រូវតែផ្តល់ប្រាក់ឈ្នួលសមរម្យ ការពារសិទ្ធិការងារ និងផ្តល់បរិយាកាសការងារប្រកបដោយសុវត្ថិភាព។ គោលនយោបាយគាំទ្រគ្រួសារ ដោយទទួលបានលំនៅឋាននិងជម្រើសថែទាំកុមារ ដែលមានតម្លៃសមរម្យ នឹងជួយលើកកម្ពស់សុខុមាលភាពរបស់មនុស្សជំនាន់ក្រោយ។

ការធ្វើឱ្យប្រសើរឡើងនូវចីរភាពនៃកំណើន និងកត្តាជំរុញទានា ក៏ពាក់ព័ន្ធនឹងការធ្វើពិពិធកម្មលំហូរពាណិជ្ជកម្ម និងការវិនិយោគផងដែរ។ នោះគឺ ការធ្វើពិពិធកម្មផលិតផលនាំចេញនិងទីផ្សារ និងប្រភពនាំចូល ក៏ដូចជាប្រភពលំហូរការវិនិយោគផ្ទាល់ពីបរទេស (FDI) នឹងកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះ ពីការប៉ះទង្គិចតាមប្រទេស និងការប៉ះទង្គិចខាងក្រៅផ្សេងៗទៀត ហើយបង្កើនចីរភាពនៃកំណើនសេដ្ឋកិច្ច។

កំណើនបៃតង ប្រកបដោយបរិយាបន្ន និងចីរភាព គឺទំនងជាមានភាពធន់។ ការផ្តល់ភាពងាយស្រួលដល់កំណើនបៃតង និងប្រកបដោយបរិយាបន្ន មានន័យថា លើកទឹកចិត្ត និងជួយកម្មករ ឱ្យផ្លាស់ប្តូរពីការងារក្រៅប្រព័ន្ធ ទៅជាការងារក្នុងប្រព័ន្ធ និងធ្វើឱ្យស្របច្បាប់ចំពោះពលកម្មទេសន្តរប្រវេសន៍ដែលគ្មានឯកសារ។ ការណ៍នេះជួយសម្រួលដល់ការអនុវត្តគោលនយោបាយដើម្បីផ្តល់ឱ្យកម្មករ និងអាជីវករខ្នាតតូចនូវជំនាញ និងភាពបត់បែន ដែលបង្កើនសមត្ថភាពពួកគេក្នុងការទប់ទល់នឹងការប៉ះទង្គិច និងវិបត្តិនានា ព្រមទាំងមានភាពធន់ក្នុងការប្រឈមនឹងដំណើរការផ្លាស់ប្តូរដែលកំពុងវិវត្ត (រួមមានការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យា)។ ការធ្វើពិពិធកម្មជួយដោះស្រាយបញ្ហានេះបាន។ ប្រព័ន្ធគាំពារសង្គមត្រូវតែពង្រីក ដើម្បីគាំទ្រដល់សហគមន៍ដែលខ្វះខាត។

## ៤.៤ សង្ខេបអនុសាសន៍គោលនយោបាយសំខាន់ៗ

កំណែទម្រង់គោលនយោបាយត្រូវការពេលវេលា ដើម្បីទទួលបានផល។ ប្រទេសកម្ពុជាត្រូវពន្លឿនការអនុវត្តកំណែទម្រង់គោលនយោបាយសំខាន់ៗ ដែលនឹងទទួលផ្លែផ្កាក្នុងរយៈពេលខ្លី និងមធ្យម ហើយទន្ទឹមនឹងនោះ ក៏ត្រូវចាប់ផ្តើមកំណែទម្រង់ជាអាទិភាពនានា សម្រាប់ការអភិវឌ្ឍកំណើនរយៈពេលវែង។ ជាពិសេស អនុសាសន៍គោលនយោបាយខាងក្រោម ទាមទារឱ្យមានភាពជាអ្នកដឹកនាំផ្នែកនយោបាយ ការផ្លាស់ប្តូរនិងការអនុវត្តគោលនយោបាយជាប់លាប់ និងការប្តូរទិសដៅនៃធនធាន និងសមត្ថភាពរបស់រដ្ឋ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអនុសាសន៍គោលនយោបាយសំខាន់ៗដែលបានជ្រើសរើស។ ការពិភាក្សាលម្អិតលើអនុសាសន៍ទាំងនេះ គឺមាននៅក្នុងឯកសារសារតារនីមួយៗ ដែលជាមូលដ្ឋានគ្រឹះសម្រាប់របាយការណ៍ទិដ្ឋភាពទូទៅនេះ។

| | |
|---|---|
| **ក** **កំណត់គោលដៅគោលនយោបាយគាំទ្រដល់អនុឧស្សាហកម្មថ្មីដែលមានសក្តានុពលខ្ពស់** | • **ទាក់ទាញវិនិយោគិនបង្គោលបរទេស**ក្នុងវិស័យអាទិភាព រួមមានការកែច្នៃកសិផល គ្រឿងអេឡិចត្រូនិក សេវាកម្មដែលអាចធ្វើពាណិជ្ជកម្មបាន និងទេសចរណ៍ ដើម្បីពង្រឹងចង្កោមឧស្សាហកម្ម និងបង្កើនសមាហរណកម្មសកល។<br>• **ដោះស្រាយបញ្ហាកកស្ទះផ្នែកបទប្បញ្ញត្តិ ហេដ្ឋារចនាសម្ព័ន្ធ និងជំនាញ** តាមរយៈការចូលរួមដែលមានរចនាសម្ព័ន្ធជាមួយវិស័យឯកជន ដើម្បីកែលម្អភាពទាក់ទាញនៃការវិនិយោគ។<br>• **ដាក់ដំណើរការក្រុមប្រឹក្សាយោបល់ត្រួតពិនិត្យការវិនិយោគផ្ទាល់ពីបរទេស** ដើម្បីវាយតម្លៃគោលនយោបាយឧស្សាហកម្ម តំបន់សេដ្ឋកិច្ចពិសេស (SEZs) និងប្រព័ន្ធលើកទឹកចិត្តការវិនិយោគជាយុទ្ធសាស្ត្រ។ |

| | |
|---|---|
| **ខ**<br>**ឆ្លើយតបនឹងអន្តរកាលបៃតងសម្រាប់កំណើនប្រកបដោយចីរភាព និងភាពធន់** | • **ពង្រីកយន្តការផ្តល់ហិរញ្ញប្បទានបៃតង** ពិសេសសម្រាប់គម្រោងថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល។<br>• **គាំទ្រដល់ឧស្សាហកម្មបៃតង** តាមរយៈការលើកកម្ពស់ការទទួលយកការប្រើប្រាស់ថាមពលស្អាត បច្ចេកវិទ្យាចាប់យកកាបូន និងដំណោះស្រាយប្រសិទ្ធភាពថាមពល។<br>• **លើកទឹកចិត្តការអនុវត្តកសិកម្មប្រកបដោយចីរភាព** ដែលកាត់បន្ថយដានកាបូន ខណៈលើកកម្ពស់ផលិតភាព។ |
| **គ**<br>**កំណែទម្រង់ដើម្បីគាំទ្រកំណើនរយៈពេលមធ្យមដែលមានមូលដ្ឋានទូលំទូលាយ និងបរិយាបន្ន** | • **ពន្លឿនការធ្វើឌីជីថលូបនីយកម្ម**ក្នុងសេវាសាធារណៈដើម្បីបង្កើនសក្តិសិទ្ធិភាព និងតម្លាភាព។<br>• **ពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅតំបន់ជនបទ** ដោយផ្តោតលើកសិករខ្នាតតូច ដើម្បីបង្កើនផលិតភាព និងការទទួលបានទីផ្សារ។<br>• **កែលម្អបរិយាកាសបទប្បញ្ញត្តិធុរកិច្ច** ដើម្បីសម្រួលដល់ការបង្កើតសហគ្រាសធុនមីក្រូ តូច និងមធ្យមជាផ្លូវការ បរិវត្តកម្មឌីជីថល និងលទ្ធភាពទទួលបានហិរញ្ញប្បទានដែលសមរម្យ។ |
| **ឃ**<br>**កសាងមូលធនមនុស្សដើម្បីវឌ្ឍនភាពសេដ្ឋកិច្ចប្រកបដោយចីរភាព** | • **កំណែទម្រង់ស៊ីជម្រៅក្នុងប្រព័ន្ធអប់រំ** ចាប់ពីមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ដោយផ្តោតសំខាន់លើភាពស្របគ្នានៃគុណភាព គណនេយ្យភាព និងកម្លាំងពលកម្ម។<br>• **ពង្រីកកម្មវិធីគាំពារសង្គម** និងដាក់ចេញគោលនយោបាយគ្រួសារមេត្រីដើម្បីទ្រទ្រង់ដល់កម្មករនិយោជិត និងសហគ្រាសធុនមីក្រូ តូច និងមធ្យម។<br>• **ពង្រឹងលទ្ធភាពទទួលបានការថែទាំសុខភាព** ដើម្បីធានាបានការគ្របដណ្តប់ជាសកល និងការកែលម្អគុណភាពសេវាកម្ម។ |
| **ង**<br>**កែលម្អអភិបាលកិច្ចជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍរយៈពេលវែង** | • **អនុវត្តកំណែទម្រង់លើប្រព័ន្ធរដ្ឋបាលសាធារណៈ និងប្រព័ន្ធគតិយុត្តិ** ដើម្បីបង្កើនសក្តិសិទ្ធិភាព និងតម្លាភាព។<br>• **បង្កើនតម្លាភាព និងភាពដែលអាចព្យាករបាននៃប្រព័ន្ធពន្ធដារ** ដើម្បីបង្កើនភាពអនុលោមទៅតាមច្បាប់ និងបង្កើតប្រាក់ចំណូល។<br>• **បញ្ជូនបុគ្គលិកបច្ចេកទេសទៅកាន់តំបន់ជនបទ** ដើម្បីគាំទ្រសកម្មភាពសេដ្ឋកិច្ច និងធានាការផ្តល់សេវាសាធារណៈប្រកបដោយសមធម៌។ |
| **ច**<br>**ជម្នះឧបសគ្គក្នុងការអនុវត្តគោលនយោបាយ** | • **លើកកម្ពស់វប្បធម៌គុណាធិបតេយ្យ** ដោយពង្រឹងសមត្ថភាពមន្ត្រីរាជការសាធារណៈដែលមានគុណវឌ្ឍិខ្ពស់។<br>• **ពង្រឹងការសម្របសម្រួលរវាងស្ថាប័នរដ្ឋាភិបាល** តាមរយៈការសម្រេចចិត្តដែលផ្អែកលើទិន្នន័យរឹងមាំ និងការបែងចែកទំនួលខុសត្រូវច្បាស់លាស់។<br>• **បង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយ និងយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ** ដើម្បីឱ្យភាគីពាក់ព័ន្ធចូលរួមក្នុងកំណែទម្រង់គោលនយោបាយ។ |

| | |
|---|---|
| **ឆ**<br>**កំណត់គោលបំណងសម្រាប់ចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា** | • **កំណត់គោលដៅដែលប្រាកដនិយម** សម្រាប់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារប្រកបដោយបរិយាបន្ន។<br>• **ពង្រឹងកម្រិតនៃសេវាសាធារណៈ និងការគាំពារសង្គម** ស្របតាមចក្ខុវិស័យប្រទេសចំណូលខ្ពស់ និងកំណត់ប្រភពចំណូលប្រកបដោយចីរភាព។<br>• **បង្កើតក្របខ័ណ្ឌបរិស្ថានជាតិប្រកបដោយនិរន្តរភាព** ដើម្បីផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចកាបូនទាប។<br>• **បង្កើតយុទ្ធសាស្ត្រសម្រាប់ការចូលរួមសេដ្ឋកិច្ចសកល** ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិ។<br>• **អនុវត្តកំណែទម្រង់អភិបាលកិច្ច និងកំណែទម្រង់ស្ថាប័ន** ស្របតាមលក្ខខណ្ឌតម្រូវនៃប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។<br>• **បង្កើតដំណើរការអភិវឌ្ឍគោលនយោបាយប្រកបដោយបរិយាបន្ន** ដែលធានាឱ្យមានការចូលរួមជាសាធារណៈក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យ។ |

# ៥. ជម្ងឺឧបសគ្គសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព

រដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ ច្បាប់ និងផែនការសកម្មភាព ដែលអាចសម្រេចបានជោគជ័យក្នុងការសម្របសម្រួលយុទ្ធសាស្ត្រកំណើនថ្មីដូចបានពិពណ៌នាខាងលើ។ បញ្ហាប្រឈមភាគច្រើនដែលបានកំណត់ខាងលើ ត្រូវបានដោះស្រាយគ្រប់ជ្រុងជ្រោយរួចមកហើយ ក្នុងក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់របស់រដ្ឋាភិបាល។ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ត្រូវបានរៀបចំឡើង ដើម្បីធ្វើសមាហរណកម្ម និងរៀបតាមលំដាប់នូវកំណែទម្រង់ដែលចាំបាច់ ដើម្បីសម្រេចបានគំរូកំណើនថ្មីមួយដែលអាស្រ័យលើជំនាញបច្ចេកវិទ្យា និងនវានុវត្តន៍។

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ បានកត់សម្គាល់បញ្ហាប្រឈមក្នុងការអនុវត្តមួយចំនួន ដោយសំដៅទៅលើបញ្ហាប្រឈមផ្នែក “សមត្ថភាព និងគុណភាពនៃស្ថាប័ន” “ប្រសិទ្ធភាពនៃការសម្របសម្រួលអន្តរក្រសួង/ស្ថាប័ន” និង “ការឃោសនា និងការផ្សព្វផ្សាយ ... ដែលប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការចូលរួម និងការគាំទ្រ”។

## ៥.១ បញ្ហាប្រឈមទាក់ទងនឹងសមត្ថភាព និងគុណភាពរបស់ស្ថាប័ន

មានបញ្ហាស្នូលចំនួនបីគឺៈ ១) វប្បធម៌ឋានានុក្រមនិយម ដែលផ្តល់អាទិភាពទៅលើភក្តីភាពជាជាងនវានុវត្តន៍ ហើយធ្វើឱ្យកំណែទម្រង់យឺតយ៉ាវ។ ២) ការប្រមូលផ្តុំថវិកា និងធនធានផ្សេងទៀតនៅថ្នាក់ជាតិ ដែលបង្អាក់ទឹកចិត្តមន្ត្រីរាជការដែលមានបំណងបន្តអាជីពនៅថ្នាក់ក្រោមជាតិ និង ៣) បញ្ហាប្រឈមនៅក្នុងគុណភាពស្ថាប័ន ឬអភិបាលកិច្ច ដែលរាំងស្ទះការផ្តល់សេវា

ប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវជំរុញទៅមុខនូវការត្រួតពិនិត្យមុខងារមន្ត្រីរាជការ និងកំណែទម្រង់ សំដៅលើកកម្ពស់ការជ្រើសរើស និងការដំឡើងតួនាទីដោយផ្អែកលើគុណាធិបតេយ្យ ធ្វើវិសហមជ្ឈការរដ្ឋាភិបាលបន្ថែមទៀត ដោយបែងចែកថវិកា និងបញ្ជូនមន្ត្រីរាជការដែលមានគុណវឌ្ឍិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៥.២ ប្រសិទ្ធភាពនៃការសម្របសម្រួលអន្តរក្រសួង/ស្ថាប័ន

មានទិដ្ឋភាពគន្លឹះបីចំពោះរឿងនេះ។ ទី១ គឺសារៈសំខាន់នៃទិន្នន័យដែលរឹងមាំ គួរឱ្យទុកចិត្ត ដែលអាចយកប្រើប្រាស់បាន និងទាន់ពេលវេលា ដើម្បីផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការពិភាក្សា និងកិច្ចព្រមព្រៀងអន្តរស្ថាប័ន។ ទិន្នន័យបែបនេះ គួរតែត្រូវបានប្រមូលដោយសេនាធិការរដ្ឋាភិបាលថ្នាក់ជាតិ និងអ្នកស្រាវជ្រាវឯករាជ្យ និងតាមរយៈវិធីសាស្ត្រដែលមានការចូលរួមពីភាគីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន។ ការអនុវត្តប្រកបដោយជោគជ័យនៃប្រព័ន្ធកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) ផ្តល់នូវគំរូវិនិច្ឆ័យយ៉ាងជាក់ច្បាស់នៅទីនេះ។ ទី២ គឺសារៈសំខាន់នៃការកំណត់អាទិភាព ដែលទាមទារឱ្យមានការបង្កើតគោលដៅ ទ្រឹស្តីនៃការផ្លាស់ប្តូរ និងផែនការអនុវត្តជាជំហាន ដោយមានគោលដៅ និងកម្មវត្ថុកម្រិតមធ្យម។ ជោគជ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេលវែងរបស់រដ្ឋាភិបាល ជាឧទាហរណ៍ដ៏ល្អមួយក្នុងរឿងនេះ។ ទី៣ គឺសារៈសំខាន់នៃការបែងចែកតួនាទី និងទំនួលខុសត្រូវច្បាស់លាស់ និងភាពជាអ្នកដឹកនាំដ៏មុឺងម៉ាត់។ ការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះវិបត្តិកូវីដ-១៩កន្លងទៅ គឺជាគំរូនៃរបៀបដែលទិដ្ឋភាពទី៣ខាងលើនេះអាចសម្រេចបាន។

## ៥.៣ ការត្រួតពិនិត្យ និងការវាយតម្លៃ

កង្វះការយកចិត្តទុកដាក់ និងការវិនិយោគលើការត្រួតពិនិត្យនិងការវាយតម្លៃ (M&E) ជាពិសេសនៅកម្រិតលទ្ធផល តម្រូវឱ្យមានជាចាំបាច់នូវវិធីសាស្ត្រដែលជាក់លាក់ និងជាប្រព័ន្ធបន្ថែមទៀត នៅគ្រប់កម្រិតទាំងអស់នៃរដ្ឋាភិបាល។ ការណ៍នេះតម្រូវឱ្យសង្កត់ធ្ងន់លើតួនាទីនៃទិន្នន័យដែលមានភស្តុតាងរឹងមាំ ទាន់ពេលវេលា និងអាចយកប្រើប្រាស់បាន ក្នុងការតាក់តែងការអនុវត្ត និងការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ។ លទ្ធភាពទទួលបានទិន្នន័យគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ជាមូលដ្ឋានសម្រាប់ការពិភាក្សា អាចលើកកម្ពស់ការយល់ដឹងរួមគ្នាអំពីបញ្ហា និងការប្តេជ្ញាចិត្តកាន់តែមុតមាំ ចំពោះដំណោះស្រាយសម្រាប់សេនាធិការនានា។

## ៥.៤ ការឃោសនា ការផ្សព្វផ្សាយ និងការគ្រប់គ្រងការផ្លាស់ប្តូរ

ផ្អែកលើអនុសាសន៍ខាងលើ ការពង្រីកការងារវិភាគដែលចាំបាច់សម្រាប់ការសម្របសម្រួលផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ក៏អាចជួយដល់ការឃោសនា និងការផ្សព្វផ្សាយផងដែរ។ ការណ៍នេះ តម្រូវឱ្យមានការងារវាយតម្លៃលើក្រុមអ្នកពាក់ព័ន្ធផ្សេងៗ ដែលរងផលប៉ះពាល់ តាមរយៈជំហានទីមួយៗនៃផែនការអនុវត្តគោលនយោបាយដែលបានស្នើឡើង រួមមានមន្ត្រីរាជការ និងភាគីក្រៅរដ្ឋាភិបាល និងបង្កើតផែនការគ្រប់គ្រងការផ្លាស់ប្តូរ ដើម្បីជូនដំណឹង អប់រំ និងគ្រប់គ្រងការឆ្លើយតបរបស់ក្រុមផ្សេងៗទាំងនេះ។

## ៦. កំណត់គោលដៅសម្រាប់យុទ្ធសាស្ត្រ ចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា

ដើម្បីជំរុញកំណែទម្រង់ និងពន្លឿនការអភិវឌ្ឍ រាជរដ្ឋាភិបាលគួរតែចាប់ផ្តើមអនុវត្តដំណើរការ ដើម្បីបង្កើតយុទ្ធសាស្ត្រចក្ខុវិស័យថ្មីសម្រាប់កំណើនឆ្ពោះទៅរកសេដ្ឋកិច្ច និងសង្គមកាន់តែស្មុគស្មាញ និងមានថាមវន្ត។ ចក្ខុវិស័យថ្មីគួរតែគូសបញ្ជាក់ពីផែនការអភិវឌ្ឍរយៈពេលវែង តម្លៃស្នូល និងគោលការណ៍ណែនាំសម្រាប់កំណែទម្រង់គោលនយោបាយ។ អ្នកបង្កើតគោលនយោបាយត្រូវឆ្លើយតបទៅនឹងកម្មវត្ថុចំនួន ៦ គឺ៖ ១) គោលដៅជាក់ស្តែងសម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាបន្នតាមរយៈកំណើនសេដ្ឋកិច្ច និងការបង្កើតការងារ ២) ការកំណត់អត្តសញ្ញាណនៃកម្រិតនៃសេវាសាធារណៈ និងកិច្ចគាំពារសង្គម ដែលរដ្ឋគួរមានដាក់គោលដៅដើម្បីសម្រេចឱ្យបាន ស្របតាមការសម្រេចបានទូវគោលដៅកំណើនរយៈពេលមធ្យម និងវែង និងប្រភពចំណូលដែលចាំបាច់សម្រាប់ផ្តល់ហិរញ្ញប្បទានចំពោះកិច្ចការនេះ ៣) លក្ខខណ្ឌតម្រូវសម្រាប់និរន្តរភាពបរិស្ថានក្នុងស្រុក និងដំណើរការផ្លាស់ប្តូរទៅកាន់គន្លងសេដ្ឋកិច្ចដែលមានកាបូនទាប ៤) យុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិរបស់កម្ពុជា ដើម្បីគាំទ្ររបៀបវារៈនៃការអភិវឌ្ឍរបស់ខ្លួន ៥) គោលដៅសម្រាប់ការកែលម្អអភិបាលកិច្ច និងស្ថាប័នជាប្រចាំ ស្របតាមភាពចាំបាច់នៃការប្រែក្លាយជាប្រទេសមានសេដ្ឋកិច្ចជឿនលឿន និង ៦) វេទិកាដែលអាចជឿទុកចិត្តបាន សម្រាប់ការចូលរួមជាសាធារណៈ ក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យគោលនយោបាយសាធារណៈ។

## ៧. សេចក្តីសន្និដ្ឋាន

គំរូនៃកំណើននាពេលអនាគតរបស់កម្ពុជាបង្ហាញថា សេណារីយ៉ូតាមដំណើរការធម្មតានឹងមិនអាចផ្តល់កំណើនសេដ្ឋកិច្ចឆាប់រហ័ស នៅក្នុងបរិការណ៍ពិភពលោកថ្មីនោះទេ។ ការវិភាគបរិបទនិងគំរូដែលបានធ្វើក្នុងការសិក្សានេះ ផ្តល់មូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រចក្ខុវិស័យថ្មីមួយ ស្របតាមភាពចាំបាច់នៃបរិការណ៍ពិភពលោកដែលកំពុងផ្លាស់ប្តូរ។ យុទ្ធសាស្ត្រកំណើនថ្មីអាចផ្តល់កំណើនគ្រប់គ្រាន់ដើម្បីទ្រទ្រង់ការអភិវឌ្ឍគុណភាពខ្ពស់ក្នុងរយៈពេលមធ្យមនិងវែង។

យុទ្ធសាស្ត្រកំណើនថ្មីមានទិដ្ឋភាពច្រើន៖ ការបង្កើតគោលនយោបាយតាមវិស័យជាក់លាក់ ដើម្បីទាញយកផលប្រយោជន៍ពីកាលានុវត្តភាពបច្ចុប្បន្ន ដើម្បីជំរុញកំណើនរយៈពេលខ្លីទៅមធ្យម ដោយ វិនិយោគលើកំណែទម្រង់ជាមូលដ្ឋាន ដើម្បីសម្រេចបានកំណើនរយៈពេលវែង ហើយដើម្បីធានាថាកំណើនត្រូវបានចែករំលែក និងផ្តល់ផលប្រយោជន៍ដល់អ្នកជំនាន់ក្រោយ និងសហគមន៍ ព្រមទាំងប្រជាជនដែលខ្វះខាត ប្រកបដោយចីរភាព និងសមធម៌។

គោលនយោបាយតាមវិស័យដែលបានលើកឡើង គឺផ្តោតលើការសម្របសម្រួលការវិនិយោគពីបរទេសបន្ថែមទៀត លើការកែច្នៃផលិតផលកសិកម្ម និងអេឡិចត្រូនិច សេវាកម្មដែលអាចធ្វើពាណិជ្ជកម្មបាន និងទេសចរណ៍ ដើម្បីទាញយកផលប្រយោជន៍ពីការកំណត់រចនាសម្ព័ន្ធខ្សែច្រវាក់ផ្គត់ផ្គង់សកលឡើងវិញ និងអន្តរកម្មបៃតង និងជួយសម្រួលដល់វិសិដ្ឋកម្មនៃសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក ដើម្បីធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធអេកូឡូស៊ីនេះ។

កំណែទម្រង់ជាមូលដ្ឋានដែលបានលើកឡើង គឺផ្តល់អាទិភាពដល់ការវិនិយោគមូលធនមនុស្ស ជាពិសេសក្នុងវិស័យអប់រំ និងសុខាភិបាល និងគំនិតផ្តួចផ្តើមគុណាធិបតេយ្យ ព្រមទាំងការវិនិយោគលើប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ សម្រាប់វាយតម្លៃការអនុវត្តគោលនយោបាយ។ អាទិភាពកំណែទម្រង់ប្រកបដោយបរិយាបន្នដែលបានលើកឡើង រួមមានការពង្រីកកិច្ចគាំពារ និងការធានារ៉ាប់រងសង្គម ការបន្តកំណែទម្រង់រដ្ឋបាលសាធារណៈឱ្យកាន់តែទូលំទូលាយ និងការគ្រប់គ្រងដ៏រឹងមាំ និងមានប្រសិទ្ធភាពនៃដំណើរការប្រកបដោយមានការចូលរួម ដែលនឹងធានាបាននូវការគាំទ្រ និងការចូលរួមពីសាធារណជន ក្នុងការរចនាតាក់តែង ការអនុវត្ត និងការត្រួតពិនិត្យដំណើរការកំណែទម្រង់របស់រាជរដ្ឋាភិបាល។

ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសដទៃទៀតក្នុងតំបន់ និងនៅក្នុងសេដ្ឋកិច្ចពិភពលោក ទាមទារឱ្យរាជរដ្ឋាភិបាលធ្វើការឆ្លើយតបឱ្យបានឆាប់រហ័សចំពោះបញ្ហាប្រឈម ហានិភ័យ និងការប៉ះទង្គិចជាច្រើន ដែលកើតឡើងក្នុងពេលតែមួយ។ ក្នុងការឆ្លើយតបឱ្យបានឆាប់រហ័សនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវប្រកាន់ខ្ជាប់នូវធាតុផ្សំ ដែលបានផ្តល់ជាគោលគំនិតនៅក្នុងយុទ្ធសាស្ត្រកំណើនថ្មីនេះ ហើយការឆ្លើយតបខាងគោលនយោបាយគួរតែជាការកសាងមូលដ្ឋានគ្រឹះសម្រាប់បញ្ហារយៈពេលខ្លី ជាជាងធ្វើឱ្យប៉ះពាល់ដល់អាទិភាពចក្ខុវិស័យកំណែទម្រង់រយៈពេលវែង៕

# ឯកសារសាវតារ

(Background papers: BP)

BP 01) Hing Vutha and Kruy Narin. February 2025. *Cambodia's Economic Trajectory: 2000-2022 Macroeconomic Analysis*.

BP 02) Ngov Penghuy and Cheng Savuth. February 2025. *Structural Transformation and Economic Growth in Cambodia*.

BP 03) Jayant Menon. February 2025. *Increasing the Inclusiveness, Resilience and Sustainability of Economic Growth in Cambodia*.

BP 04) Muth Sumontheany. February 2025. *Cambodia's Macroeconomic Review: Current State and Short-Term Outlook*.

BP 05) Eng Netra, Caroline Hughes, Ngin Chanrith, Chea Phal, and Cesci Cruz. February 2025. *Climate Change, Gender, and Social Analysis for Cambodia's New Growth Strategy*.

BP 06) Eng Netra, Caroline Hughes and Pak Kimchoeun. October 2024. *Overcoming Constraints for Effective Policy Implementation*.

BP 07) Dean Rizzeti. February 2025. *Delivering the skills for the clean energy transition*.

BP 08) Kelly Wyett. February 2025. *Cambodia Economic Diversification Pathways.*

BP 09) Roland Rajah and Ahmed Albayrak. February 2025. *Modelling Cambodia's Road to Quality Growth.*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

អគារលេខ ៥៦ ផ្លូវលេខ ៣១៥
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
លេខកូដប្រៃសនីយ៍ ១២១៥២
ទូរស័ព្ទ៖ +៨៥៥២៣ ៨៨១៧០១, ៨៨១៩១៦, ៨៨៣៦០៣
អ៊ីមែល៖ CDRI@CDRI.ORG.KH
គេហទំព័រ៖ WWW.CDRI.ORG.KH